# សម្ភាសន៍ជាមួយ គាត រុន ហៅ គាត គក់ ភេទប្រុស អាយុ៥៦ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ«យុទ្ធជនកងវរសេនាតូច១៦០»

## កើតនៅភូមិស្រែជ្រៃ ឃុំជង្ក្រង់ ស្រុកក្រចេះ ខេត្តក្រចេះ

## សព្វថ្ងៃរស់នៅភូមិសែនសម ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

## ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៣

## សម្ភាសន៍ដោយៈ ឌី ខាំបូលី

## ០១: ០៧ :២៥

## ៣៩ទំព័រ

បូលីៈ ពូឈ្មោះអីពូ?

រុនៈ នែក៎ គក់!

បូលីៈ ប៉ុន្តែឈ្មោះក្នុងបញ្ជីជាតិ?

រុនៈ រុន! ក្នុងឃុំនេះដាក់ឈ្មោះ គក់ ។

ប្រពន្ធៈ បើនៅក្រចេះ គក់ អត់ស្គាល់ទេ ។

រុនៈ គក់អត់ស្គាល់ទេ ។

បូលីៈ គក់អត់ស្គាល់ទេណ៎?

ប្រពន្ធៈ អត់ស្គាល់ផង ។

បូលីៈ ក្នុងបញ្ជីជាតិត្រកូលអី?

រុនៈ គាត!

បូលីៈ គាត រុន?

រុនៈ គាត គក់ណា៎!

បូលីៈ ឥលូវ ខ្ញុំដាក់អានេះមួយទៀតចោះ! គាត រុន អាមួយនេះទៀតចោះ ។

រុនៈ ឈ្មោះដើម ។

ប្រពន្ធៈ បើនៅក្រចេះស្គាល់គាត រុន ។

បូលីៈ សព្វថ្ងៃ ពូអាយុប៉ុន្មានហើយ?

រុនៈ ៥៦ ។

បូលីៈ ៥៦! ពូកើតឆ្នាំប៉ុន្មានចឹង?

រុនៈ គិតទៅមើល អើ! វាភ្លេចឆ្នាំទៅហើយ១៩៥៣ ទេមិនដឹង ។

បូលីៈ ៥២, ៥៣?

រុនៈ ១៩៥២ នៅមិនខុសទេ ។

បូលីៈ ស្រុកកំណើតនៅភូមិស្រុកខេត្តអីអ៊ី?

រុនៈ ក្រចេះយើងនេះ ។

បូលីៈ ភូមិឃុំ?

រុនៈ ឃុំជ្រុងជ្រន៍ ។

បូលីៈ ភូមិអីគេ?

រុនៈ ភូមិកសាង ។

ប្រពន្ធៈ យកភូមិឯនេះ ឬក៏ស្រុក?

បូលីៈ ស្រុកកំណើត ។

រុនៈ ស្រុកឯនោះណ៎ា មិនមែនយកនេះណ៎ា ។

បូលីៈ បាទ!

រុនៈ ភូមិស្រែជ្រៃ! ឃុំជ្រុងជ្រន៍ ។

បូលីៈ ហ្នឹងហើយ ។

រុនៈ ស្រុកក្រចេះខេត្ត ខេត្តក្រចេះ ។

បូលីៈ បាទ! ហើយបច្ចុប្បន្ននេះ?

ប្រពន្ធៈ ភូមិសែនសម ។

បូលីៈ ឃុំ?

ប្រពន្ធៈ ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។

បូលីៈ ខេត្តឧត្តរមានជ័យ! បាទ! ភូមិសែនសម ។

ប្រពន្ធៈ ឃុំអូរស្វាយទៀត ។

បូលីៈ ត្រពាំងប្រាសាទយើង?

ប្រពន្ធៈ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។

បូលីៈ ហើយប្រពន្ធកូនឈ្មោះអី មីង?

ប្រពន្ធៈ ខ្ញុំឈ្មោះ សែង គួយ ។

បូលីៈ សែង គួយ! មីង អ្នកស្រុកណាដែរ?

ប្រពន្ធៈ ស្រុកកំណើត?

បូលីៈ ស្រុកកំណើត ។

ប្រពន្ធៈ ភូមិពកតាឆ្នួន ។

បូលីៈ		ឃុំអីគេ?

ប្រពន្ធៈ		ឃុំ អន្លង់សាឡី ក៏មិនដឹង ។

បូលីៈ		អន្លង់សាឡីៗ! នៅស៊ឹងត្រង់? ស៊ឹងត្រង់ កំពង់ចាម?

ប្រពន្ធៈ		ចាស ។

បូលីៈ		បើមីងមកបានច្បាស់ គាត់អ្នកដីដុះ ។

ប្រពន្ធៈ		ដីដុះហ្នឹង ឃុំជាមួយគ្នា ។

បូលីៈ		ឃុំជាមួយគ្នា! នៅក្នុងឃុំអីគេ?

ប្រពន្ធៈ		នៅនេះ ។

បូលីៈ		អត់ទេ! ដីដុះណា៎ ។ ឃុំដីដុះ ឬក៏ឃុំអីគេ?

ប្រពន្ធៈ		ខ្ញុំចាកមកពីស្រុកយូរហើយណា៎ ។

បូលីៈ		ឆ្ងាយហើយណា៎ ។

ប្រពន្ធៈ		ទេ! មើលពកគាងួន ព្រះអណ្ដូង ពាម ដីដុះ ជាប់ៗគ្នាហ្នឹងឯង ។

បូលីៈ		ជាប់ៗគ្នាណា៎?

ប្រពន្ធៈ		ចា៎ស!

វុនៈ		កាលផ្ទះឯង ផ្ទះសម្ដេច?

បូលីៈ		ជិតភូមិស្ដេចដែរ?

វុនៈ		បាទ! នៅវត្តថ្មីនេះឯង ។

បូលីៈ		ពូកូនប៉ុន្មានហើយឥលូវ?

ប្រពន្ធៈ		កូនខ្ញុំមិនចេះតិចទេ១០ក្បាល ។

បូលីៈ		កូន១០នាក់?

ប្រពន្ធៈ		កូន១០នាក់ នៅតែ៩ទេ! ងាប់នៅស្រុកមួយ ។

បូលីៈ		វាឈឺអី?

ប្រពន្ធៈ		វាឈឺគ្រុនក្ដៅ វាគ្រុនឈាម ១១ខែ ទៅលេងស្រុកកាលផ្ដាច់ខ្លួន ។

បូលីៈ		ហើយសព្វថ្ងៃនៅ៩! រៀនបានប៉ុន្មានហើយ?

ប្រពន្ធៈ		បាន៣ហើយ នៅ៦ ។

បូលីៈ		នៅ៦ទៀត?

ប្រពន្ធៈ		ចា៎ស!

បូលីៈ		ច្រើនដែរ?

ប្រពន្ធ៖ គ្រាន់តែកូនវង្វេងខ្លួន។ ឈឺក្បាលជន្លង់បាត់។

បូលី៖ ហើយពូចេញពីស្រុកមកឆ្នាំប៉ុន្មាន?

ប្រពន្ធ៖ តាំងពី៧៣មក។

បូលី៖ ចេញហ្នឹង ចេញយ៉ាងម៉េច យើងស្ម័គ្រចិត្ត ឬក៏គេទៅណែនាំ?

វុន៖ អត់ទេ! សម័យនេះគឺម៉ែពុកហ្នឹងអត់ ម្ដាយពូណាគាត់ ធ្វើប្រធានសហករណ៍ ទាំងពុកទាំងម៉ែធ្វើប្រធានសហករណ៍សម័យ៣ឆ្នាំ។ បញ្ជូនកូនមកចូលកងទ័ព។

បូលី៖ ប៉ុន៧៣ មិនទាន់?

វុន៖ សិល្បះទេ។ ៧៣ សិល្បៈ វាយអាមេរិចនេះទេ។

បូលី៖ បាទ! វាយអាមេរិចកាំងណា?

វុន៖ ខ្ញុំចូលខាងសិល្បៈ។

បូលី៖ ពូខាងសិល្បៈ?

វុន៖ ខាងសិល្បៈចឹងទៅ យើងច្រៀងកសិករក្រីក្រ កំពង់ធ្វើការហ្នឹងណាំ ភ្លេងផង សិល្បៈផង។ មួយសារហ្នឹងនោះ លេងភ្លេង ដេញតាខេ ទ្រកូដ ធ្វើសិល្បៈ ចឹងទេកាលហ្នឹង។ ចេញតាំងពី៧៣ពីផ្ទះ រហូតមកដល់ឥលូវទៀតណាំ។

បូលី៖ ចេញហ្នឹង ចេញទៅណាដំបូងចេញ?

វុន៖ សម័យនោះចេញទៅ សម័យប៉ុល ពតយើងហ្នឹងណាំ។ ចេញទៅដើម្បី។

បូលី៖ ធ្វើអី? ធ្វើជាយុវជន ឬក៏?

វុន៖ យុវជន! យុវជន ខាងសិល្បៈ។

បូលី៖ ខាងសិល្បៈ?

វុន៖ បាទ!

បូលី៖ សិល្បៈឃុំ ឬសិល្បៈ?

វុន៖ សិល្បះស្រុកតែម្ដង ទេសិល្បៈ ឃុំនៅជន្ត្រង់។

បូលី៖ ហូ!សិល្បៈ ឃុំជន្ត្រង់?

វុន៖ ស្រុកក្រចេះ ខេត្តក្រចេះ។

បូលី៖ នរណាគេប្រធានសិល្បៈ?

វុន៖ បងសី។

បូលី៖ ឈ្មោះអីសី?

វុន៖ សីនៅភូមិចាស់យើងសព្វថ្ងៃ ខាងវិចិត្រសិល្បៈ។

ប្រពន្ធៈ ឆាប់ហើយខាងសីនោះ ។

បូលីៈ ប្រពន្ធកូដទ្រចេះ?

វុនៈ បងសី! បងសីស្រីនេះ ។ គាត់ច្រៀងសិល្បៈ តំបន់៥០៥ ជាដើម ពីសម័យប៉ុល ពត ។

បូលីៈ តំបន់៥០៥? តំបន់ក្រចេះ?

វុនៈ ទេ! តំបន់ក្រចេះ៥៥៥ ។

បូលីៈ ៥០៥?

វុនៈ ៥០៥ហ្នឹងហើយ ។ ៥៥០!

បូលីៈ ហើយឪពុកម្ដាយពូ ប្រធានសហករណ៍?

វុនៈ ប្រធានសហករណ៍ ។

បូលីៈ ប្រធានសហករណ៍ ឃុំអីគេ?

វុនៈ ភូមិជ្រគ្រាំ កសាង ឃុំស្រែជ្រៃយើងនោះ ។ សម័យអាប៉ុល ពតយើងនេះ ភូមិកសាង ។

បូលីៈ ភូមិកសាង?

វុនៈ ភូមិកសាងប្រជាជនថ្មីច្រើនពេក ដែលវាយអាមេរិច៧៥ ធ្វើអីរួចហើយនោះ គាត់ប្រមូលអ្នកមកពីវៀតណាមដាក់នៅភូមិកសាង ស្រែជ្រៃ នោះ ដាក់ភូមិកសាងថ្មីទៅ ។

បូលីៈ បានន័យថាភូមិស្រែជ្រៃ ពេលហ្នឹងឈ្មោះនៅដដែរទេ?

វុនៈ ប៉ុន្តែបង្កើតភូមិថ្មីហ្នឹង គេដាក់ភូមិកសាងថ្មី នៅសម័យប៉ុល ពត ។

បូលីៈ បានន័យថាភូមិកសាងហ្នឹង ទើបបង្កើតនៅសម័យប៉ុល ពតទេ? មិនមែនតាំងពីជំនាន់សម័យសង្គមរាស្ត្រនិយមទេ?

វុនៈ មិនមែនទេ! ភូមិស្រែជ្រៃទេ, ស្រែជ្រៃ, ស្វាយយូរ, គម្ពីរ ។

បូលីៈ ចឹងស្រែជ្រៃ ជាមួយកសាង នៅក្បែរគ្នា?

វុនៈ ក្បែរគ្នា! របងផ្ទះសព្វថ្ងៃ ពុកម៉ែបងប្អូនមួយភូមិ និយាយទៅបងប្អូនចង់ទាំងអស់ ។

បូលីៈ ចឹងបានន័យថាភូមិកសាងហ្នឹង កើតរហូតដល់ឥលូវ?

វុនៈ ឥលូវ ។

បូលីៈ ចេញពីកំណើត ពីសម័យប៉ុល ពត?

វុនៈ ពីសង្គមនោះ គឺស្រែជ្រៃ ដល់សម័យប៉ុល ពត គេដាក់ភូមិកសាង ។ គេកសាងថ្មីប្រជាជន ដែលវាយអាមេរិចអីអស់ហើយ ជម្លៀសមកឲ្យនៅធ្វើទំនប់ធ្វើអីហ្នឹង កសាងគេដាក់កសាងហ្នឹង ។

បូលីៈ ចុះការរស់នៅក្នុងសហករហ្នឹងយើងរស់នៅយ៉ាងម៉េច? យើងមានឯកជនចេះទេ ឬក៏មាននៅជុំគ្នា?

រុនៈ អត់ទេ! គ្មាននៅឯកជនបានទេ។ ប៉ុន្តែបងនោះនៅធ្វើទាហានប្រចាំ ឆ្ងាយពីពុកម៉ែណាស់ គេបញ្ជូនទៅ មិនទៅ។

បូលីៈ ទៅណាស់?

រុនៈ ទៅប្រចាំនៅ ដ-៤យើងនោះ ដ-៤ ។

បូលីៈ ដ-៤ ។

រុនៈ នៅក្រចេះ សម័យប៉ុល ពតនោះ មិនដ-៤ ។

បូលីៈ អត់ស្គាល់ទេ!

រុនៈ ដ-៤ ធ្លាប់ឃើញ។ មើលនេះ អាផ្ទះថ្ម ពីសង្គមស៊ីវិលផ្ទះថ្មគេនោះ។

បូលីៈ នៅទីរួមខេត្ត?

រុនៈ នៅទីរួមខេត្តនោះឯង អាផ្ទះថ្មពីសង្គមនោះ។ មិនទៅខាងកើត(ស្តាប់ពុំបាន) ។ ដ-៤ចេះហើយ (ស្តាប់ពុំបាន) ខាងត្បូង។

បូលីៈ ហ្ន៎! អាប៉ូលីសវាលវង់?

រុនៈ គេហៅដ-៤(ស្តាប់ពុំបាន) ។ គេហៅដ-៤!

បូលីៈ ហើយកន្លែងទាហានធំរបស់ខេត្តក្រចេះនៅម្តុំណា?

រុនៈ នៅដ-៤ហ្នឹង។

បូលីៈ ដ-៤តែម្តង?

រុនៈ ដ-៤តែម្តង! ប្រមូលកម្លាំងទ័ព កម្លាំងតាមភូមិ តាមស្រុកអី ទៅនៅដ-៤ទាំងអស់ដើម្បីបញ្ជូនទៅវាយ។

បូលីៈ នរណា គណៈមេធំនៅក្រចេះហ្នឹង?

រុនៈ ទេ! ពីសម័យប៉ុល ពត ដែលសម្លាប់ តា ឃី គាត់គណៈខេត្តពីដើមកាលហ្នឹង ពីសង្គមសីហនុ។

បូលីៈ តាឃី!

រុនៈ ចុះបើគាត់គណៈខេត្តពិសេសហ្នឹង ពីសង្គមសីហនុ ពីសង្គមហើយពីសម័យ៣ឆ្នាំ តាអីគណៈខេត្តបីឆ្នាំ ភ្លេចឈ្មោះបាត់ហើយ។

បូលីៈ មិនមែនឃី គួន នេះទេ គណៈខេត្តក្រចេះ សម័យ ប៉ុល ពត?

វុនៈ បាទ! យី គួននេះឯង ។ ប៉ុន្តែកូនគាត់ទេណា៎! គាត់ធ្វើល្អដែរ ប៉ុន្តែគេថាធ្វើអាក្រក់ៗ ក៏អាក្រក់ទៅ ទៅតាមដំណើររបស់គេទៅ ។

បូលីៈ ចុះបន្ទាប់ពីយី គួន ពីណាគេទៅ?

វុនៈ យី គួន មក ដល់ពេលចាប់យីគួនទៅបាត់ សុទ្ធតែពួកខាងនែក៎នេះទេមក ពួកខាងនេះ!

បូលីៈ និរតី?

វុនៈ និរតី! គេចាត់តាំងថ្មី ឡើងកាន់អំណាចហ្នឹង ។

បូលីៈ ឈ្មោះអី?

វុនៈ មិនដឹងឈ្មោះអីទេអូន ។

បូលីៈ ពូដែលស្គាល់តា អែម សារិន ទេ?

វុនៈ តាម អែមសារិន នៅ!

បូលីៈ នៅក្រុមប្រឹក្សាស្រុកណា៎?

វុនៈ ហ្នឹងហើយ! នៅនែក៎ ។

បូលីៈ ត្រពាំងប្រាសាទណា! តា អែម សារិននៅជិតមន្ទីរបក្សប្រជាជន! អែម សារិន តាជន នោះ ។

វុនៈ តា ជន គាត់ខាង នេះជាមួយតា ញ៉ាន់-០៣ហ្នឹង ហ៎ូ! មួយឆ្នាំ តាជនយើងចឹងស្លាប់ ហើយ ដាក់ឈ្មោះអ ី អែម សារិន?

បូលីៈ បាទ!

វុនៈ មហាសម្លាប់គេ ។

បូលីៈ ចឹងហ៎េ?

វុនៈ មិនបាច់ទេ! វាយ គាត់ថាបេះ គាត់មកប្រចាំការ គាត់នៅនោះឆ្ងាយ ហើយមិនមែនអ្នក ខេត្តក្របេះយើងទេ ។

បូលីៈ មិនមែនទេ!

វុនៈ តាកែវ!

បូលីៈ តា ឌុល ពេលដែរ យី គួនហើយ!

វុនៈ តា ឌុល ហ្នឹងមក ។

បូលីៈ ជាមួយ!

វុនៈ ជាមួយ តាញ៉ាន់ សាម៉េន ។

បូលីៈ តាញ៉ាន់?

រុនៈ មេទ័ព! (ស្តាប់ពុំបាន) តារុន នោះគាត់កាន់មន្ទីរពេទ្យ ជាមួយប្រពន្ធគាត់ ។
បូលីៈ ប៉ុនគាត់កាន់ខាងមន្ទីរពេទ្យ ឬកាន់ខាងក្រចេះទាំងមូល?
រុនៈ គាត់អ្នកដើងឯកខាងប្រយុទ្ធនេះ បាក់ដើងកាលហ្នឹងដោយសាររឿងកាន់កាប់នៅខេត្តនេះ ទេបន្ទាប់មក! ខ្ញាំងណា តារុន ។
បូលីៈ គាត់យ៉ាងម៉េចដែរ គាត់ស្លូត ឬក៏កាច?
រុនៈ មិនជាកាចទេ ប៉ុន្តែគ្រាន់តែថាស្លូត ស្លូតផង នេះមើលទៅដូចជាមិនស្លូតទេ ដល់ឃើញគាត់ចឹងមួយៗ នឹកឃើញថាយើងអួរឬស្សីប្រាប់ឲ្យហើយ ។ ខ្ញុំព្រួមាត់ចឹង!
បូលីៈ ចឹងហ៎! ខ្លាចគាត់នោះ?
រុនៈ ចុះបើសម័យ ប៉ុល ពត យើងហាន ចុះបើគេកាន់អំណាច យើងហាន ។
បូលីៈ គាត់ដែលសម្លាប់មនុស្សដែរ ឬទេ តា ឌុល?
រុនៈ មិនទេ! គាត់គ្រាន់តែអ្នកបញ្ជា គេអ្នកធ្វើ(ស្តាប់ពុំបាន) គ្រាន់តែខេត្តគេឲ្យមកចឹងណ៎! បងនៅជាមួយគាត់ណ៎ សួរតាឌុលមើល ។
បូលីៈ ពូនៅជាមួយគាត់ដែរ?
រុនៈ នៅជាមួយខ្ញុំ ងាប់ហើយ ។
បូលីៈ នៅធ្វើអី?
រុនៈ យើងវាយចូលរដ្ឋាភិបាល ចូលប្រទេសទាំងអស់ហើយណ៎ ។
បូលីៈ កាលពីក្រចេះមក ពូមាននៅជាមួយគាត់នៅក្រចេះ?
រុនៈ នៅក្រចេះអត់បានជួបគ្នាទេ ប៉ុន្តែឈ្មោះគាត់នៅប្រចាំនៅ!
បូលីៈ ព្រួសួរតែឈ្មោះ ឌុល តែម្តងទៅ?
រុនៈ ព្រួតែឈ្មោះ ឌុល! នៅខេត្តក្រចេះ មកពីនិរតី ។
បូលីៈ ចុះប្រធានយោធាធំពីណាគេ?
រុនៈ ប្រធានយោធាធំ?
បូលីៈ ពេលនៅជំនាន់ យី គួនណ៎ យោធាខេត្ត?
រុនៈ យោធាខេត្ត! អត់ទេ អត់ដឹងទេ ព្រោះយើងគ្រាន់តែកាន់កាប់ កងទ័ព ដឹងតែកងទ័ព តែប៉ុណ្ណឹង ។
បូលីៈ ចុះតាហឿន?
រុនៈ តាហឿនគាត់៦១២ ។
បូលីៈ ៦១២ណ៎?

រុនៈ ៦១២ ។

បូលីៈ គាត់មាននៅក្របេះដែរទេ តាហឿន?

រុនៈ នៅក្របេះ ។

បូលីៈ គាត់មេទ័ពទេ មើលទៅ?

រុនៈ មេទ័ព មកវាយធ្វើផ្ទះដួលអីមកវាយដេកនោះ ។

បូលីៈ ពួបូលធ្វើទាហាន ពួបូលធ្វើកងពលណា៎!

រុនៈ កងពល១៦០ ។

បូលីៈ ប៉ុន្មាន?

រុនៈ វរសេនាតូច១៦០ ។

បូលីៈ កងពលអីគេ?

រុនៈ កងពល៥៥៥ហ្នឹង កងពល!

បូលីៈ ៥០៥?

រុនៈ ៥០៥ ក្របេះហ្នឹង ។

បូលីៈ ៥០៥ ក្រែងជាឈ្មោះតំបន់តា ។

រុនៈ ឈ្មោះតំបន់ ប៉ុន្តែនែ៎ក ដាក់បេះទៅ! ហ៎ូ!១៨០ ។

បូលីៈ ១៨០ហ្នឹងហើយ ។

រុនៈ ១៨០ ។

បូលីៈ ក្របេះនេះ មានប៉ុន្មានកងពលក្របេះ?

រុនៈ ទេពីសម័យប៉ុល ពត អត់មានទេ មានតែម្នាក់ទេ ។

បូលីៈ ពីសម័យ ប៉ុល ពតក្រែងមានពីរកងពលអី?

រុនៈ ដឹងពីរអីទេ!

បូលីៈ មានអីខ្លះ?

រុនៈ ចាំមើលណា មានវរៈ១៦០ ហើយ១៨០ ដាកល់វរសេនាធំ១៨០ ។

បូលីៈ វរសេនាធំ?

រុនៈ វរសេនាធំ១៨០! ១៦០ ។

បូលីៈ ១១០?

រុនៈ ១១០ តា (ស្តាប់ពុំបាន)

បូលីៈ បឹងមិនមែនវរសេនាធំទេបឹង?

រុនៈ	វរសេនាធំ!

បូលីៈ	អត់មានកងពលទេចឹង?

រុនៈ	កងពល! គ្មានកងពលទេ ។ កងពលឯណាមាន អត់ ។ មានតែកងពល មកវាយតាញ៉ន់អី មក ពីកងពលកំពង់សោមទៅវាយ ។ ក្រៅពីនេះអត់មានកងពលទេ ។

បូលីៈ	១២០មានទេ?

រុនៈ	១២០អត់មានទេ ។

បូលីៈ	១៣០?

រុនៈ	១៣០ អត់មានទេ ។

បូលីៈ	មានតែ១៨០តែម្ដង?

រុនៈ	១៨០ ។

បូលីៈ	មានវរសេនាធំ១៨០ ហើយហ្នឹងវរសេនាធំ១៦០ ហើយមិនមែនកងពលទេ ។

រុនៈ	គ្មានកងពលទេ ។

បូលីៈ	ពូនៅ១៨០?

រុនៈ	ហ្នឹងហើយ ។

បូលីៈ	ពីណាគេមេ១៨០?

រុនៈ	បឿន ។

បូលីៈ	បឿន ហ្នឹងអ្នកខាងណា?

រុនៈ	គាត់នៅខាងកោះកុង ។

បូលីៈ	មកពីចម្ងាយ ឬយ៉ាងម៉េច?

រុនៈ	មានពីឆ្ងាយ ។

បូលីៈ	ចុះមុន បឿន មកដល់ពីណាគេ?

រុនៈ	មុនបឿន! គួន ។

បូលីៈ	យី គួនហ្នឹង?

រុនៈ	យី គួនយើងនៅ(ស្ដាប់ពុំបាន) ពីដើម ។

បូលីៈ	យី គួន គណៈស្រុក គណៈខេត្ត?

រុនៈ	អត់ទេ! យី គួនហ្នឹងស្រលាញ់ប្រពន្ធណាស់ណា៎ យីគួន ហ្នឹងគណៈខេត្ត ។ គួន មួយទៀត ណា៎!

បូលីៈ	គួនមួយទៀត ។

រុនៈ គ្រាន់តែ កាលហ្នឹងគេយកគាត់ទៅសម្លាប់ចោល ។

បូលីៈ គួនហ្នឹងអ្នកក្រចេះ?

រុនៈ អ្នកក្រចេះយើង ។

បូលីៈ បឿន?

រុនៈ បឿន មកពីកំពង់សោម ។

បូលីៈ បឿន មកពីខាងកំពង់សោម?

រុនៈ មកពីខាងកំពង់សោម គេមកកាន់កាប់វរៈ១៨០ ។

បូលីៈ ហើយគួនអ្នកអូរប្ញស្សី?

រុនៈ គួន អ្នកអូរប្ញស្សី ។ សម័យ ប៉ុល ពតយកមកមុនណ៎ា ដល់អានេះមក គាត់(ស្តាប់ពុំបាន) គាត់យកទៅសម្លាប់ចោល ។

បូលីៈ បឿនហ្នឹង យកគួនទៅសម្លាប់ចោល ។

រុនៈ បាទ!

បូលីៈ ចុះ១១០ ពីណាគេ?

រុនៈ ១១០ ដំបូងបំផុត ពីណាគេ?

បូលីៈ ចាំមើលណ៎ា!

រុនៈ ក្រោយទេ ១១០ តាអ៊ីត ។

បូលីៈ តាអ៊ីត ក្រោយទេ!

រុនៈ ក្រោយ!

បូលីៈ ចុះតាណ៎ាមុន តាអ៊ីតទៀត?

រុនៈ យូរហើយ ។ បើអ៊ីតហ្នឹង (ស្តាប់ពុំបាន)

បូលីៈ មកពីណាតាអ៊ីតហ្នឹង?

រុនៈ មកពីលិចហ្នឹង ។

បូលីៈ ពីកំពង់សោម ឬក៏និរតី?

រុនៈ កំពត ។

បូលីៈ កំពតហ៎េ!

រុនៈ ដូចអាគាងចឹង មិន!

បូលីៈ ចុះ១៦០ ពីណាគេ?

រុនៈ ១៦០នែក៎នេះ ព្រឹម ។

បូលីៈ មុនព្រីមហ្នឹង មានពីណាទៀតទេ?

រុនៈ អត់មានទេ មានតែព្រីម ។

បូលីៈ ព្រីម អ្នកនៅណា?

រុនៈ ព្រីម ពួកខាងនិរតី ។ ខ្ញុំទេអ្នកនិរសារគាត់ ។

បូលីៈ ក្រែងពួកនោះ១៨០?

រុនៈ ១៨០ ។

បូលីៈ ប៉ុន្ដែ ព្រីម១៦០?

រុនៈ ដាក់១៦០នៅត្រូវហើយ ។ អាហ្នឹងវរៈ!

បូលីៈ និរតីដែរ?

រុនៈ និរតី ។

បូលីៈ ខេត្តណា? កំពត ឬក៏តាកែវ?

រុនៈ ដាក់ខេត្តកំពត មិនដឹងខាងអីៗទេ ។ ខ្ញុំហ្នឹងហើយ និរសាគាត់ ។

បូលីៈ ពូនៅ១៨០ ឬ១៦០?

រុនៈ ខ្ញុំ១៦០ ។

បូលីៈ មិនមែន១៨០ទេ?

រុនៈ ១៨០ មេ ។

បូលីៈ កន្លែងមេ?

រុនៈ កន្លែងមេវរសេនាធំ១៨០ អានេះ ។ ១៨០ បញ្ជូនទៅ៨ ទេតានេះណា តាវរៈណា ១១០ អានេះហើយ សុទ្ធតែ១១០ ។ ១៨០គឺកន្លែងរួម ដូចកន្លែងកងពលចឹងណា វរសេនាធំ យល់ទេ តែប៉ុណ្ណឹងទេ ។

បូលីៈ ចុះ១១០ ១៦០នេះវរសេនាធំ វរសេនាតូច?

រុនៈ វរសេនាតូច ។ តូចទេ! ១៨០ បានវរសេនាធំ ។

បូលីៈ ចឹង១១០នេះវរសេនាតូច?

រុនៈ វរសេនាតូច ។

បូលីៈ អានេះតូចដែរ?

រុនៈ ១៦០ហ្នឹងវរសេនាតូច ។ មានតែ៣វរៈទេ ។ មិនហានកអបលទេ អានេះវរសេនាធំ ប្រចាំកែវសីមាថាមណ្ឌលគីរី ។

បូលីៈ ១៨០ ក្រែងនៅក្រចេះអី ម៉េចក៏ទៅនៅមណ្ឌលគិរីវិញ?

រុនៈ ក្រចេះ! ទៅខាងព្រំដែនជាមួយតា០៦ហ្នឹងមិន(ស្តាប់ពុំបាន) ទល់គ្នា ខាងនេះខេត្តក្រចេះ ខាងនោះតា០៦ ប្រចាំគ្នាព្រំដែនៗណា៎ ហើយវៀតណាមខាងមុខ ហើយទល់ដែនបែកគ្នា ។

រុនៈ ខាងស្នួលចឹង?

បូលីៈ នៅស្នួល ។ ពូមានទៅស្នួលអីទេដែរចឹង?

រុនៈ ហ៊ូ ដ-៤ ។ (ស្តាប់ពុំបាន) កន្លែងវរសេនាធំ ដ-៤ ភូមិថ្កូងយើង! ជិតផ្ទះវៃ ខនប្រធានភូមិនៅថ្កូង ហើយគេថាស-១៦០ ។

បូលីៈ ហើយវរៈ ណាខ្លះគេទៅចាំនៅព្រំដែន?

រុនៈ មានតែ១១០ ហើយហ្នឹង១៦០ ។

បូលីៈ ១៨០អត់ទេ?

រុនៈ ១៨០ ហ្នឹងវរៈ!

បូលីៈ ១៨០ នៅក្រចេះ?

រុនៈ បាទ! អត់នៅក្រចេះទេ នៅស្វាយជ្រះអីនោះណា៎ ។

បូលីៈ ស្វាយជ្រះ?

រុនៈ ស្វាយជ្រះ!

បូលីៈ ខាងកន្ទួតនោះវិញ ។

រុនៈ មិនមែនកន្ទួតក្រចេះ ឯនោះទៀតណា៎ ផ្លូវជាតិលេខ១៣ ។

បូលីៈ ផ្លូវជាតិលេខ១៣ ស្រុកអី?

រុនៈ ស្រុកកែវ សីមា ។

បូលីៈ ស្រុកកែវ សីមា!

រុនៈ ខេត្តក្រចេះយើងនេះ ទាហានទាំងអស់ទៅចាប់ដៃជាមួយតា០៦ នៅ កែវសីមាហ្នឹងឯង ទៅចាប់ដៃនេះឯង ។

បូលីៈ ការពារព្រំដែនព្រំដែន!

រុនៈ អីនោះក៏ចាប់ដៃគ្នា ព្រំដែនយួននោះឯង(ស្តាប់ពុំបាន) ទៅផ្លូវមេព្រៃរបស់យើង ។

បូលីៈ អានេះមណ្ឌលក្រចេះណាពូ ។

រុនៈ (ស្តាប់ពុំបាន)

បូលីៈ នេះកែវសីមានេះ នៅក្បែរហ្នឹងឯង ។

រុនៈ នៅកែវសីមា!

បូលីៈ នេះកែវសីមា ។

រុនៈ នៅកែវសីមា ត្រូវហើយ!

បូលីៈ អានេះស្អួល?

រុនៈ ស្អួល!

បូលីៈ ចឹងមកចាប់ដៃគ្នានៅកែវសីមានេះឯង ។

រុនៈ កែវ សីមាននេះ ។

បូលីៈ ការពារព្រំដែន ជាមួយយួន ។

រុនៈ បាទ! យួន ។ របស់គេផ្សេង?

បូលីៈ បាទ!

រុនៈ ផ្លូវ! មេព្រៃពីដើម ពីសង្គមយើងនោះ បានយើងខាងមណ្ឌលគីរីហ្នឹងក្រចេះ ចាប់ដៃគ្នានៅកែវសីមាហ្នឹងឯង ។

បូលីៈ បាទ!

រុនៈ អានេះ គេថា១៦០ ។

បូលីៈ ១៦០ហេ៎?

រុនៈ ១៦០ មកចាប់ដៃតា០៦នេះឯង ។ ការពារព្រំដែនយើង មួយសារពាឆ្នាំនោះ ។ ទល់តែឃើញដែនទី បានខ្ញុំថាអ៊ូ! ចាំច្បាស់ គេថាកែវ សីមា មកជាមួយប្អូនខ្ញុំ ។

បូលីៈ ហើយដល់តែ ពេលយួន វាយចូលមករត់ទៅណា៎ទៅ?

រុនៈ យួន វាយចូលមក បងមកពីទប់ទល់ជាងគេណា៎ ។

បូលីៈ បាទ!

រុនៈ មកដល់ផ្ទះៗ ហើយបងចេញមកនៅអីស្រុកវិញ ។

បូលីៈ នៅកំពង់ចាម!

រុនៈ នៅភ្នំជី!

បូលីៈ អ៊ូ! ភ្នំជី កំពង់ធំ?

រុនៈ កំពង់ធំ ។

បូលីៈ មកនៅឯកំពង់ធំ?

រុនៈ នៅភ្នំជី ស្រុកសណ្ដាន់!

បូលីៈ នៅសណ្ដាន់នែក៎! នៅនែក៎ភ្នំជី មកនៅកៀកហ្នឹងសម្បូរណា៎?

វុនៈ បាទ! ហ្នឹងឯង កៀកសម្បូរយើងនោះឯង ។

បូលីៈ សម្បូរនៅខាងចេន នៅខាងអី!

វុនៈ សម្បូរនៅខាងចេន នៅខាងអី(ស្តាប់ពុំបាន)

បូលីៈ ភ្នំដី! អត់ទាន់ឡើងភ្នំទេចឹង?

វុនៈ អត់ទាន់ឡើងទេ!

បូលីៈ នៅភ្នំដីប៉ុន្មានឆ្នាំ?

វុនៈ គិតទៅ១ឆ្នាំ!

បូលីៈ ១ឆ្នាំ!

វុនៈ អត់បាយស៊ីទេ!

បូលីៈ ហើយបានអីហូបទៅចឹង?

វុនៈ ស៊ីក្តួច ស៊ីអីទៅ! មនុស្សរាប់ម៉ឺន សុទ្ធតែមេៗ មិនមែនអ្នកតូចៗណា ។

បូលីៈ ប្រមូលពីក្រចេះហ្នឹងមក?

វុនៈ ទាំងអស់និយាយរួម ទៅហ្នឹង ។

បូលីៈ ចុះមុនមកដល់ភ្នំដី ពូគិតឆ្លងទន្លេមេគង្គ?

វុនៈ មិនឆ្លងយ៉ាងម៉េច ឆ្លងពីផ្ទះយើងហ្នឹងមកនៅភ្នំដីហ្នឹង ។

បូលីៈ ឆ្លងតាមម្តុំណា៎?

វុនៈ ឆ្លងនៅអាអើកោះដំបង ។

បូលីៈ កោះអីគេ?

វុនៈ កោះដំបង កោះងាវ កោះដំបងយើងនេះ ។

បូលីៈ អ៊ូ៎! ឆ្លងសម្បូរហ៎េ ។

វុនៈ សម្បូរ! ឆ្លងអីលើ លើសម្បូរ ។

បូលីៈ ចឹងរត់ពីក្រចេះទៅសម្បូរសិន?

វុនៈ សម្បូរ!

បូលីៈ ហើយបានឆ្លង!

វុនៈ ឆ្លងពីទន្លេមេគង្គ មកលិច ។

បូលីៈ មកលិច មកភ្នំដី ។

វុនៈ ចាប់ផ្តើមកម្លាំងទាំងអស់ ប៉ុន្មានកងពល ប៉ុន្មាននាក់នៅណែនណាន់តាន់តាប់ រាប់ម៉ឺន!

បូលីៈ បើអ្នកខ្លះគេហួសទៅស៊ឹងត្រែង?

រុនៈ		អ្នកខ្លះគេទៅស៊ីងត្រែង អាខ្លះទៅកោះកុង បើក្រចេះយើងអត់បានទៅណាទេ មកដល់គិប នៅហ្នឹងតែម្តង នៅភ្នំដីយើងហ្នឹង ។

បូលីៈ		វាយហើយទៅអត់ទាន់?

រុនៈ		វាកៀក វាទៅអត់ទាន់! ចុះភ្នំពេញគេចូលអស់ហើយ មានអីក្រចេះយើង(ស្តាប់ពុំបាន) មកដល់ភ្នំដីហ្នឹង ទល់បង្អែកជាប់បណ្តោយ ក្លួចរលាយ ។

បូលីៈ		ក្រចេះមានក្លួចដែរ?

រុនៈ		ក្លួចស្រូវបងប្អូន ហ្នឹងគេដាំចឹង គេឲ្យប្រូតណ៎! ប៉ុន្តែយើងងាប់ៗច្រើនដែរ ដោយសារធ្វើម៉េចឲ្យបានរស់ ទោះបីជាងាប់យ៉ាងណ៎ ធ្វើម៉េចឲ្យបានស៊ី ទោះបាញ់ ទោះចាក់គ្នា ។

បូលីៈ		ហើយនៅភ្នំដីហ្នឹង ប៉ុន្មានឆ្នាំ?

រុនៈ		១ឆ្នាំ ។

បូលីៈ		ម៉េចបានយើងមកឡើងភ្នំនៅដល់១ឆ្នាំ?

រុនៈ		ចុះបើមេយើង គេខ្មែរក្រហមគេមិនទាន់រៀបចំឲ្យស្រួលផងហ្នឹង ។

បូលីៈ		មេមួយណា?

រុនៈ		ទល់តែដឹងហើយ ដឹងថាតា! តាប៉ុល ពត ។

បូលីៈ		នរណាគេអ្នកដឹកនាំ ភ្នំដីហ្នឹង?

រុនៈ		បើនិយាយទៅពីមុនដែលសែង បើនិយាយទៅ សែងតាខៀវមក គាត់នៅកន្លែង តាពក ខ្មោចតា!

បូលីៈ		ហ៎ូ! សែងតាខៀវមកដែរ?

រុនៈ		តាពក គាត់កាន់កាប់!

បូលីៈ		នៅភ្នំដីហ្នឹង.?

រុនៈ		បាទ! នៅភ្នំដី គាត់មេទ័ពធំខ្មោចតាពក ៤១៧ ហើយគាត់នៅកណ្តាល គាត់កាន់កាប់មើលទាំងអស់ ។

បូលីៈ		កែ ពកមើលការខុសត្រូវភ្នំដីហ្នឹង?

រុនៈ		កាន់កាប់ទាំងអស់! ចឹងហើយ កងទ័ពបាក់បែក មកពីណាអស់ហើយ! គាត់ធ្វើមេតែម្តងទៅ ។

បូលីៈ		ខ្ញុំឮសួរថាតា សុន សេន គាត់នៅក្រចេះដែរ ពេលយួនបែកចូល ។

រុនៈ		នៅក្រចេះមែន តែការពិតគាត់មកនៅ!

បូលីៈ		ហើយពីណាគេអ្នកសែងគាត់?

រុនៈ បើនិយាយទៅ បើសម្លាស់ល្អិតតិច ពិបាកនិយាយដែរ ព្រោះអីគ្មានខ្លាំងដល់អន្តរក្ស គាត់ទេ នៅរស់ ។

បូលីៈ ពួសូរតែគេសែងគាត់ពីក្រចេះមកណា៎?

រុនៈ សែងមកដាក់ភ្នំដីហ្នឹង សែងយកមកដាក់នៅអូរស៊ីងឆ្វាំង ហើយសែងយកទៅដាក់ភ្នំទៀត ។ មិនសែងយ៉ាងម៉េច គាត់ដើររួចមែន គាត់គិតច្រើនពេក សែងតែម្តង ។ កងពិសេសប៉ុន្មាន រាប់រយនាក់ អមសងខាងយកទៅតែម្តង អត់ញៀមញ៉ុមទេ ។

បូលីៈ សែងពីម្តុំណាពូ?

រុនៈ យកពីអូរស៊ីងឆ្វាំងចេញទៅ ។

បូលីៈ ចេញឡើងលើភ្នំអី?

រុនៈ អូនហើយ! ចាស់ទុំណា៎ គាត់ក្បត់ជាតិមែន តែបងក៏ក្បត់ជាតិដែរ គ្រាន់តែអាណិត អាហ្នឹងមនុស្សរាប់ម៉ឺនណា៎ មិនមែនពាន់ទេណា៎ ។ រាប់ម៉ឺន ចុះបំណាច់ គេវាយពីនោះ មកហើយ យើងមិននេះសិន(ស្តាប់ពុំបាន) អាខ្លះមិនរាប់ហ្នឹងក្តួច ។

បូលីៈ ពុល?

រុនៈ មិនពុលទេ! តែវាខ្វះជាតិណា៎ ក្នុង១ឆ្នាំ វាខ្វះជាតិអន្តរយើងណា៎ ។

បូលីៈ ហើយតាកែ ពក គាត់នៅហ្នឹងដែរ ឬក៏អត់ទេ?

រុនៈ គាត់នៅហ្នឹង ។

បូលីៈ គាត់អត់ឡើងភ្នំទេ កាលហ្នឹង?

រុនៈ គាត់ឡើងចុះឡើងៗ ដឹងជញ្ជូនឥវ៉ាន់ ចុះឡើងៗ ។

បូលីៈ គាត់ដឹកជញ្ជូនឥវ៉ាន់ឲ្យយើង?

រុនៈ ផ្តល់ឲ្យយើងខាងក្រោមនេះ ខ្ញុំហ្នឹងហើយនៅផ្ទាល់ជាមួយគាត់ ។

បូលីៈ ហ៊ូពូធ្លាប់នៅជាមួយគាត់?

រុនៈ នៅកងពិសេស ។ បង្រៀនទៅវាលំបាក ពូថាថ្ងៃគាត់ចេញទៅកំពង់ចាម ទាហានចាំ វាយរហូត ។ យកមកវិញ! ចុះឡើងៗបីងណា៎ ជួនកាលឲ្យកងទ័ពនេះទៅវាយ ។

បូលីៈ កាលនោះឆ្នាំ៨០?

រុនៈ ៨១, ៨២, ៨៣ ដល់៨០ប៉ុន្មាននេះទៀត និយាយទៅទើបតែសមាហរណកម្ម ទល់រហូត មក ។

បូលីៈ ពេលណាបានពូឡើភ្នំ ឆ្នាំប៉ុន្មានបានពូឡើងភ្នំ?

រុនៈ ឆ្នាំ៨០ ។

បូលីៈ ឡើងប៉ុន្មាននាក់កាលហ្នឹង ។

រុនៈ ឡើងមួយសារហ្នឹងវា ជិត១០០០នាក់ ។ ងាប់អស់១០០ជាង! អត់អី ងាប់នោះរដ្ឋាភិបាលវាយទេ វាយតាមផ្លូវបារាំងនោះ ។ ក្នុងអត់បាយស៊ី មកដេកតាមផ្លូវនោះ បាញ់យកភ្នាមនោះ ។

បូលីៈ ១០០០នាក់ហ្នឹង ។

រុនៈ នៅសល់តែ៧០០ ឡើងទៅរួច ។

បូលីៈ ទាំងកងទ័ព ឬក៏?

រុនៈ ទាំងកងទ័ពហ្នឹង ទាំងមីងៗនិយាយរួម ។

បូលីៈ ទាំងមីងៗដែរ?

រុនៈ ទាំងអស់ ។

បូលីៈ ក្មេងៗដែរ ។

រុនៈ ក្មេងដែរ ព្រោះអីវាគ្មានអីស៊ី បើមិនរស់ឆ្នាំ៨០ទៅដល់លើភ្នំគឺស្លាប់ហើយ ។ តាៗទាំងអស់ហ្នឹងទម្រាំយកអង្ករពីបារាំងស្អីៗណា មកកក្រើកគគ្រេង អាខ្លះឃ្លានបាយពេក ដាំប៉ោតយកអង្ករដាក់នៅហ្នឹងប៉ោត ។ ដាំនៅហ្នឹងប៉ោត យកទៅដាក់នៅប៉ោត អាប៉ោតប្រហុកគេធំៗណា៎ ។ ដាំបាយស៊ីឡើងឆ្អែត អាខ្លះស៊ីឡើងងាប់ក៏មានដែរ ព្រោះវាឃ្លានណា៎ ។ បងខ្ញុំគីន ស្លាប់ដោយសារតែស៊ី ។

បូលីៈ ចឹង?

រុនៈ វាហាវ ។ ឲ្យបងឡើងទៅមុន!

បូលីៈ ស៊ីច្រើនពេក ។

រុនៈ ស៊ីវាឃ្លាន គេ(ស្តាប់ពុំបាន)គាត់ឃ្លាន គ្រាន់តែឡើងភ្លាប់ គ្រាន់តែឃ្លានបាយ ដាំបាយឯលើសស៊ីៗងាប់បណ្តោយ ក្រពះវាអត់មានកិន ។

បូលីៈ ក្រពះវាកិនអត់ទាន់ វាណែនក្តន់ ។

រុនៈ ១០០០ប៉ុន្មានរយទេ ឡើងមួយសារហ្នឹង ។ ចឹងកងពិសេសនៅប្រចាំ ឲ្យគេឡើងទៅសិន ខ្ញុំអត់ឡើងទេ ។

បូលីៈ អីគេ០៣?

រុនៈ ០៣គាញ៉ាន់ ។

បូលីៈ គាញ៉ាន់! អ៊ូ! គាញ៉ាន់០៣ណា៎?

រុនៈ ០៣ កងពិសេសនោះ០៣! ដូចបងម៉ារី ។

បូលីៈ	គាញ៉ន់ គេហៅគា០៣ហ៎?

រុនៈ	០៣ ។ គាត់ថាឈ្មោះដែរសម័យដែល ប៉ុល ពតដែលគាត់នែក យើងបែកបាក់គ្នាណា៎ ដាក់ឈ្មោះគាត់០៣ទៅ ។ ០៣ មានតែគាហ្នឹង ។

បូលីៈ	គា០៥ គាសារឿន?

រុនៈ	គាសារឿន ។

បូលីៈ	០៦ គាសាន ។ ចុះ០៧ មានទេ?

រុនៈ	គាហឿនៗបេះ ។

បូលីៈ	ចុះ០៩?

រុនៈ	ចុះវាបំបែកគ្នាបេះ ពេលយើងនេះបំបែកគ្នា វាច្រើនកងពលណា អត់ចាមដែរ ។

បូលីៈ	ចឹងគាញ៉ាន់ គាត់នៅភ្នំដីដែរចឹង?

រុនៈ	ភ្នំដី ។

បូលីៈ	គាញ៉ាន់កងពលលេខប៉ុន្មានពេលមកនៅ?

រុនៈ	៨១៧ ។

បូលីៈ	គាត់អនុទេ?

រុនៈ	អ៊ូ! មេប្រធាន ។

បូលីៈ	ប្រធាន?

រុនៈ	គាត់ស្លាប់ហើយ ។

បូលីៈ	ក្រែងគាពកអីប្រធាន?

រុនៈ	គាពក ។

បូលីៈ	ចុះគាញ៉ាន់?

រុនៈ	គាញ៉ាន់ គាត់នៅជាប់កំពង់សោមហ្នឹង ។

បូលីៈ	កំពង់សោម?

រុនៈ	បាទ! មកជួយហ៎ វាយមួយខាងហ្នឹង គាត់កងទ័ព គាត់កាន់ទ័ពដែរហ្នឹង០៨អី ។ គាត់មិន ០៣ទេ គាត់ដូរឈ្មោះទេ ។

បូលីៈ	គាត់ដូរទេ! ដូរក្រោយមកទេ?

រុនៈ	ដូរក្រោយទេ ។

បូលីៈ	ពីមុនហៅគាញ៉ន់ៗ!

រុនៈ	ហៅគាញ៉ន់ៗទេ! មកកំពង់សោម(ស្តាប់ពុំបាន) នោះភូសល់ ។

បូលីៈ គាញ៉ាន់ហ្នឹង មកពីកំពង់សោម?

វុនៈ កំពង់សោម ។

បូលីៈ មកពីខាងណា៎? ខាងអើ! កោះខ្យងអី?

វុនៈ ហ្នឹងហើយ! ម្តុំហ្នឹង ។

បូលីៈ ខាងតាមុតហ៎? មាសមុត?

វុនៈ អត់ទេ! គេខាងនោះ ខ្ញុំ!

បូលីៈ ផ្សេង!

វុនៈ បើគេដាក់ខេត្តក្រចេះដឹងតែម្តង ។

បូលីៈ ដល់ពេលឡើងភ្នំហ្នឹងពូ ពូឡើងមកភ្នំមួយណា?

វុនៈ នៅ១០០១ មុំ៣នោះ?

បូលីៈ ហ៎! មុំ៣ នៅ១០០១ ។

វុនៈ ហ្នឹងហើយ!១០០៣ ។! ដាក់ចេះត្រូវ ។

បូលីៈ ពីណាអ្នកគ្រប់គ្រងធំនៅ១០០១ហ្នឹង?

វុនៈ កន្លែងហ្នឹង៤១៧ មានតា ពក ។

បូលីៈ ចុះពេលតា ពក ហើយមេលើតាពង់នោះពីណាគេ ។

វុនៈ តែ៤១៧ទេណា៎ ។

បូលីៈ បាទ!

វុនៈ មេហ្នឹងទៀតអត់ដឹងទេ ។ គេមានមេគេ ធំនៅលើហ្នឹងទៀត ។

បូលីៈ តា ពក គាត់នៅ១០០១?

វុនៈ ១០០១! កងបលធំណា៎ ។

បូលីៈ ឡើងមកដល់១០០១ ពូការនៅការហ្នឹង?

វុនៈ ប្រពន្ធខ្ញុំយកឆ្នាំ៨០ ។

បូលីៈ ចុះប្រពន្ធមុន?

វុនៈ ប្រពន្ធមុននៅហ្នឹង! យកឆ្នាំ៨០ ។ ៧៩,៨០ យកតែម្តង ។

បូលីៈ យកនៅណា៎?

វុនៈ យកនៅភ្នំដីយើងហ្នឹង ។

បូលីៈ ហ៎ូ! ពូការនៅភ្នំដីទេ?

រុនៈ បងប្អូនឯង ។

បូលីៈ ជីដូនមួយទេ ។

រុនៈ ឃើញវាឈឺ ហត់ពេក ។ យកបងប្អូនឯងទៅ! ខ្លាចងាប់ ។ យកវាចិញ្ចឹមខ្លាចវាងាប់នោះណា៎ អាខ្លះងាប់អស់ទៅឃើញបងប្អូនឯង ។ កូន ក្រត៉ុ យាយនី យកប្អូនគ្នាសិន ខ្លាចបងប្អូនងាប់! អាខ្លះ ឃើញដេកអង្រឹងចឹងទៅហាវងាប់ យកបងប្អូនគ្នាឯង ។ ស្តាយប្អូនស្តាយប្រពន្ធយកទៅដាក់នៅបារាយនោះវត្តដំណាក់ ទុកចោលផ្ទះតាចឹង ទៅ ។ ខ្ញុំមកនៅភ្នំជីវិញនៅព្រៃអីភូមិនេះទេ ។ បើមិនចឹងងាប់ប្អូន អាហ្នឹងងាប់ក៏ងាប់ទៅ មិន ដឹងធ្វើម៉េចវាហាវណា៎ ធ្វើយ៉ាងម៉េចឲ្យជីវិតខ្លួនឯងរស់សិនស្លាប់ប្អូន ។ ឲ្យនៅផ្ទះ នៅភូមិ វាបណ្តោយ ដល់យប់ឡើង ខ្ញុំយកសាច់ជ្រូក សាច់ប្រើសពីព្រៃចឹងទៅឲ្យ ហើយគាត់ថា កុំយកទៅឲ្យច្រើនពេក ចិត្តបានណាស់យកទៅឲ្យប្រពន្ធ ដល់ពេលចឹងទៅបានគេបាញ់ ។ យប់ហ្នឹងវាប្រលំទេ ខ្ញុំស្មានថាគ្នាឯង(ស្តាប់ពុំបាន) បើពីដើមចាំថាប្រពន្ធ នឹងមានការអីវានៅផ្ទះតាហ្នឹង ចាំបាញ់ចឹងបានត្រូវ ។

បូលីៈ ហ៎ូ! ដែលពួយកម្អូបទៅឲ្យប្រពន្ធនោះហ្នឹង?

រុនៈ បាទ!

បូលីៈ វៀតណាម ចាប់បាញ់តែម្តង?

រុនៈ មួយគ្រាប់ងាប់២នាក់ ។

បូលីៈ ទៅប៉ុន្មាននាក់?

រុនៈ ទៅបីនាក់ ។ ដល់ពេលចឹងស្តាយ សាច់ប្រើស សាច់ទន្សោង ហ៎ូភ្នំជីយើងពីដើមប្រើសឡើងបបូរ ។ មិនបាញ់បុកដើមឈើទេ មិនបាច់(ស្តាប់ពុំបាន) នោះវិល អាពីរនាក់នោះបែកក្បាលខ្ទេច ។ មិនបាញ់បុកនោះទេ បាញ់បុកពាក់កណ្តាល បានជាខ្ញុំបាញ់វិញ ។ ងាកមកខ្ញុំបាញ់អស់១២គ្រាប់អា(ស្តាប់ពុំបាន) ។ បាញ់គ្នាបាញ់អស់ដកដង្ហើមអត់ស្រួលទេ រត់! វាទៅបាក់ឆ្អឹងជំនីទៅហើយ ។ អា២នាក់នោះនៅហ្នឹងសិនទៅ កាំភ្លើងមួយដើមនរណាយកក៏យកទៅ ។ កាន់អិម-១២ នោះបាញ់ឡើងខ្ទេចខ្ទីងពេក ដើរចេញបណ្តោយ ។ ទម្រាំដល់ភ្នំជី អូរស៊ីងឆ្ងាំងមាននៅជិត ណា៎ឆ្ងាយណាស់ណា៎ ។ ទៅដល់ក៏ដេកតាមផ្លូវ បានអាអាចមកយក អាអាចវានៅសម្បូរវាមកយកកងព្រះវិហារ ។

បូលីៈ ម៉េចបានដឹង?

រុនៈ វាអត់ដឹងថាបាត់ ពួកកាំភ្លើងខ្លាំងពេក ផ្ទុះខ្លាំងពេក ចេញមកតាមផ្លូវពីអូរស៊ឹងឆ្លាំងភ្នំដីមកដល់(ស្តាប់ពុំបាន) ប៉ុនកុំចូលណា៎ តែចូលកាំភ្លើងអាកាមួយដើម អឹម១ដើម គ្រាប់បែកទៀត។ បើនៅកណ្តាលផ្លូវប្រសាង អាផ្លូវក្រហមភ្នំដីហ្នឹង ចេញពីអាចេនទៅហ្នឹង ផ្លូវសៀមរាបហ្នឹង។ អាអាចនោះ នៅសម្បូរទៅយក ថាបងច្បាស់ជា វាមកយក។ អានោះគ្រាន់តែឃើញខ្ញុំវារបួសចឹង ឈាមខ្លាំងពេក វាលីខ្ញុំ លើកលីទៅបណ្តោយគ្រាប់កាំភ្លើងចោលពេញព្រៃ លី! ទៅដល់នេះតាពេទ្យនេះវះបង្ហូរឈាមចោល វាបាក់អាឆ្អឹងជំនីខ្ញុំ (ស្តាប់ពុំបាន) វាបោកចំទទឹង បុកចំសាប់ហើយ ចេះទទឹងវាវាយបោកដឹកថាអានេះអត់ត្រូវដៃទេ អានេះខ្ទេចនៅតែក្បាលទេ ហា៎កម្មណា៎! ហើយដើម្បីជាតិចុះជាតិឡើងឯងលើងរហាម ចង់ធ្វើអីធ្វើទៅខ្ពិល។

បូលីៈ បាក់ឆ្អឹងជំនីហ្នឹង នៅដើរបានទៀតណា៎?

រុនៈ បាន!

បូលីៈ យី! អស្ចារ្យតែម្តងណា៎។

រុនៈ គេវះកាត់យក វះនៅ១០០១នេះ ទៅវះនៅ១០០១។

បូលីៈ អត់វះនៅភ្នំដីទេចឹង?

រុនៈ អត់វះទេ! យកទៅកាត់ឆ្អឹងចោល បើមិនកាត់យ៉ាងម៉េចខ្លាចវារលួយ ឆ្អឹងជំនីខ្ញុំ គាត់ដេរបើថ្មេរ កាត់ចោល(ស្តាប់ពុំបាន)អូរហើយបើសិនជារលួយទៅសាប់បណ្តោយ ព្រោះគ្មានលុយ។

បូលីៈ ពេទ្យគេជំនាញណាស់ណា៎ពូ?

រុនៈ ហា៎មិនបាច់និយាយទេរឿងនោះ ពេទ្យចិន។

បូលីៈ ហូរចិន!

រុនៈ មួយសារនោះនៅ។

បូលីៈ ចិនជួយ។

រុនៈ (ស្តាប់ពុំបាន) ឲ្យខ្មែរយើងឈ្មោះគ្នា និយាយទៅវាហួសហេតុពេក បើនិយាយប្រវត្តិសាស្ត្រវិញសាប់ យ៉ាប់ណាមួយភូមិនេះសាប់អស់ហើយមួយជំនាន់បង នៅតែបងទេ ដូចថាវារឹងមាំដែរ របូតរកស៊ីសព្វថ្ងៃចឹង។ (ស្តាប់ពុំបាន)ទាំងអស់តា០០២០ខ្លះត្រឹមនេះ អស់ហើយ ហើយអាខ្លះមកជិតៗ(ស្តាប់ពុំបាន) ធ្វើម៉េចយើងត្រូវតែធ្វើ ការពាតាមបន្តៗតាមដំណាក់ៗណា៎ ដល់ពេលសម័យនេះ សម័យនោះសំណាក់នោះ ឲ្យកូនយើងដឹងខ្ញុំពន្យល់កូនខ្ញុំចឹង តាមសង្គមធ្វើយ៉ាងម៉េចសង្គ្រាមវាមាន! វាមានជំនាន់វា។ ការពារ

ប្រទេសយើងអត់កើតទេ ឲ្យគេឲ្យអស់ប៉ុណ្ណឹងហើយ កូនដឹងថាមើលសម័យនោះទៀត បើគេមាន រឿងមានរ៉ាវអីចេះទៀត រឿងរបស់គេ គេតៗក៏ទៅ មានតែគុណប៉ុណ្ណឹងហើយ បានកូន មើលអីមើលថាឪពុកវាអស់ហើយ ទាំងអស់គ្នាអ្នកស្លាប់ទៅ សុំដើម្បីជាតិដែរ ប៉ុន្តែធ្វើម៉េច យើងអគុណពេកហើយ ។ យើងបានទឹក បានដីក៏វាល្អដែរ សមាហរណកម្ម ដល់នេះ ខ្ញុំអរ ។ បើកុំតែសមាហរណកម្មខ្ញុំងាប់បាត់ហើយ មិនមែនលេងទេណា៎អូន បាន សមាហរណកម្មការឈ្នះៗជាមួយសម្ដេចទាំងអស់ទាំង ខាងនេះទាំងនោះ! ដើរច្បាំងគ្នា រាល់ថ្ងៃទៀត ងាប់បាត់ ។ គ្រាន់តែគ្រាប់កាលមុននេះផ្ទុះកូនណានោះងាប់ទីនេះ ។

បូលីៈ គ្រាប់អីគេ?

រុនៈ គ្រាប់អា៨០ ។អាំងភ្លើង ស្រាប់តែខ្ញុំទៅចម្ការអាម្ដុំប៉េអឹមប៉ូលីសគេមកព្រាតចឹងទៅណា៎! វាឆេះៗដល់ហើយ ទៅតាមនេះគ្រាប់ហ្នុ៎វានេះ វាយគ្នាងាប់ ។

បូលីៈ ស្លាប់ប៉ុន្មាន?

រុនៈ អត់មានស្លាប់ទេ ។

បូលីៈ របួសទេ?

រុនៈ អត់មានរបួសទេ! កូនខ្ញុំវាចេះអត់មានអាំង អាំងភ្លើងអាឆ្នាំទៅ ឆ្នាំទៅ១អត់មានអាំងទេ វាចេះដើរចេញ ឡើងមាំងផ្ទះបងបងបែកអ៊ូ៎! កុំអីហ្នឹងខ្ញុំងាប់មួយពូជអស់ ហើយពូណា៎ គេចេះតែកត់ អត់មានស្អីទេ ទៅមិនបាច់ចូលទេ! ខ្ញុំក៏ថាចឹងមិនបាច់ទេ កុំរញ៉េរញ៉ៃ ។ ប៉ូលីសគ្រាន់តែតោះ បើធ្វើឯណាកត់ត្រា កត់អីឯណា! មិនដឹងមុខ មិនដឹងមាត់ទេតោះ ថយចេញ ខ្ញុំខឹងណា៎! ទើបតែមកពីចម្ការ ឃុំបារ៉ៃ ទៅមិនបាច់ទេដឹងហើយ អត់ទេ ហែង អញកប់ដីអញ ។ ដល់កពេកខឹងណា៎!

បូលីៈ ខឹងរឿងអីពូ?

រុនៈ ខឹងចិត្តថារាប់សម័យយើងវាយកូនមិនដឹង ខឹងចិត្តខ្លួនឯងវាហួសចិត្ត ចៀសជាងកូនឯងរស់ បើផ្ទុះងាប់ ចុះបើគ្រាប់ផ្លោងគ្រាប់អីវាយនេះណា៎ ខ្លះផ្ទុះខ្លះអត់ចឹងទៅណា៎ យើងដុត ភ្លើងវាក្ដៅ យើងអត់ដឹងថាគ្រាប់ហ្នឹងផង ។

បូលីៈ អត់ដឹងនេ៎?

រុនៈ អត់ដឹង! ពីហ្នឹងមក ប្រពន្ធកូនអីងាប់ មិនចេះកូនដើរចេញអស់ងាប់! ខ្ញុំវា៨០អាធំ នោះកក្រើកណា៎ ហើយអាពួកស៊ីម៉ាក់អីណា៎នោះ ។

បូលីៈ មករកអត់ឃើញ!

រុនៈ ទៅគ្រាប់កប់ដីដល់ កប់ទៅគ្មានឃើញទេ ទៅរកឯណា រហូត១ឆ្នាំៗទៅ(ស្តាប់ពុំបាន) ចឹងៗមិនទេ ៗ អត់អស់ទេ!

បូលីៈ ឥលូវអាចសល់ទៀតទេពូ?

រុនៈ គ្រាន់តែចម្ការបងផង គរឈើទុកចោល ៗ

បូលីៈ ចឹង?

រុនៈ ពួកស៊ីម៉ាក់ ពួកនេះគេអត់ប្រាប់ទេ បើប្រាប់វានាំគ្នាដើររកអើយដើររក ៗ រកគេបានលុយប្រាក់ខែគេណា៎! មួយគំនរ ប៉ុនបងចេះទៅតា នឹកថាអូនឯងអាយុប៉ុណ្ណេះខ្វះ បងឃ្លាននំបញ្ចុកពេកថ្ងៃហ្នឹង អត់មានលុយសោះ ឃ្លាននំបញ្ចុក ឃ្លានអើយឃ្លានៗ ទៅលក់គ្រាប់អាសម័យនោះមួយគំនរណា៎ លក់ឲ្យអេតចាយ ម៉ូតូគេយកទៅដាក់ លក់បាន១៥០០០ មកទិញនំបញ្ចុកស៊ី ចុះបើទុក គរវាច្រើនពេក ប្រាប់គេប្រាប់ដល់ពួកអ្នករាវហ្នឹង គេមិនជឿ ដល់ពេលរើសអេតចាយលក់អស់! ក្បត់ណា៎ គ្រាប់ខ្មែតាម៉ុក គ្រាប់ខ្មែផ្ទុះតែម្តងដាក់មីនតាមផ្លូវ វៀតណាមវាយរដ្ឋាភិបាលមិនបានទេអាក្រក់អាក្រើណា៎ ៗ ៦០គ្រាប់ដាង!

បូលីៈ មីនអី?

រុនៈ ទាំងមីន៦៩ ទាំងគ្រាប់៨០,៦០ ព្រោះឃ្លាននំបញ្ចុកពេក វាអត់លុយ ៦០ ហ៊ូខ្ទេច ៗ

បូលីៈ អត់ខ្លាចផ្ទុះទេ?

រុនៈ មួលក្បាលដោះចោល ៗ

បូលីៈ ហ៊ូ! ដោះក្បាលចេញហើយ ៗ

រុនៈ ដោះក្បាលចេញ! ប៉ុណ្ណោះ លក់ឲ្យអេតចាយ ពួកនោះច្បិចយកទៅ ៗ

បូលីៈ ចុះអាពេលដែលកំពង់មួលយើងអត់ដែរផ្ទុះទេ?

រុនៈ អត់ទេ!

បូលីៈ ដឹងរបៀបគេ?

រុនៈ ដឹងរបៀបគេហើយ ៗ ខ្មែរបស់ផ្ទុះ អូនឯងកុំព្រួយ! សាប៊ូសាកមើលនេះយើងដាក់មកមកដាក់ឲ្យ មើលផ្ទុះមាំងបណ្តោយ ឆ្ងាញ់បាយអាសាប៊ូយើងនេះហ្នឹង ហើយហ្នឹងអំបិលអ៊ីយូតដាក់មកកាត់ឲ្យ អំបិលបន្ទុះប៉ុណ្ណេះឯងដាក់មើលទៅមនុស្សខ្ទេច ៗ អំបិលយើងខ្លាំងណាស់អាអំបិលអ៊ីយ៉ូតហ្នឹង ឆ្ងាញ់ចឹងហើយយើងនិយាយសម័យអាខ្មែប្រឌិតអានៅសល់ណាស់ ៗ

បូលីៈ យើងខ្មែអីខ្លះ ខ្មែអាថ្មពិល?

រុនៈ ថ្មពិល!

បូលីៈ ស្អីទៀតទៅពូ?

វុនៈ ថ្មពិលយើងអាតូចៗ ថ្មែប៉ុណ្ណេះដាក់(ស្តាប់ពុំបាន) អំបិលយើងក៏បាន ហើយសាប៊ូយើងនេះ អំបិលខ្លាំងជាងគេ ។

បូលីៈ ខ្លាំងដែរ

វុនៈ ខ្លាំងណាស់ ។

បូលីៈ វាមានរំសេវបានខ្លាំងម្ល៉េះ?

វុនៈ រហ័សខ្លាំងណាស់ ។

បូលីៈ ពេលពូព្យាបាលនៅ១០០១នេះព្យាបាលរយៈពេលប៉ុន្មាន?

វុនៈ ៣ខែ!

បូលីៈ យូរដែរ ។

វុនៈ ៣ខែបានជា ចុះបុកដល់នេះត្រូវពោះធំ វាដំបៅពោះធំ ។

បូលីៈ ពោះវៀនធំ!

វុនៈ វាដំបៅហ្នឹង ដល់ដំបៅវាឆ្លុះមើលតិចទៀតឲ្យនេះបីខែ បីខែរួចហើយ គេយកទៅកំពង់ចាម ។

បូលីៈ បញ្ជូនមកក្រោមវិញ?

វុនៈ មកក្រោមវិញ! កំពង់ចាមវាយ ។

បូលីៈ មកកំពង់ចាមនេះ?

វុនៈ ភ្នំដី!

បូលីៈ មកភ្នំដីវិញ?

វុនៈ បាទ! មកមើភ្នំដីវិញ ។

បូលីៈ មកភ្នំដី មកកន្លែងដដែរ ឬខុសគ្នា? មកកន្លែងដែលពូនៅពីមុន ឬក៏?

វុនៈ អូរស្ពឹងឆ្នាំង! មកពីកន្លែងភ្នំដីមកអូរស្ពឹងឆ្នាំងហ្នឹង ។ មកកន្លែងដដែរ(ស្តាប់ពុំបាន) មកផ្ញើរទីហ្នឹង យើងមិនធ្វើការនៅទីហ្នឹង ។

បូលីៈ ហើយប៉ុន្មានឆ្នាំ បានឡើងទៅវិញម្តង?

វុនៈ បើខ្វះមួយឆ្នាំ បានគេឲ្យទៅ បើបង៣ខែ ។

បូលីៈ ម៉េចចឹង?

វុនៈ ចុះបើគេដឹកគ្រាប់មក!

បូលីៈ ពូអ្នកជញ្ជូនគ្រាប់?

រុនៈ អ្នកជញ្ជូនគ្រាប់មកឲ្យគេៗ មកម្ដង៣០០នាក់!

បូលីៈ មិនមែនវាយទេ?

រុនៈ អត់វាយទេៗ បើសិនជាវាយ គេហៅថាកងពិសេស កន្លែងតាពកនេះ ពួក៥២នេះ តែវាយហើយក៏ស្ដុក វាយចូលកន្លែងណា៎ផ្សារអីកន្លែងណាវាយហើយ វាយសិន ហើយ គ្រាប់ឲ្យគេអស់ហើយ ទន្លេសាបទន្លេអីឲ្យគេអស់ហើយ ឲ្យតែគេមកដឹក យកអស់ហើយៗ ម្ដង១០០០គ្រាប់ ម្ដង៧០០ ទៅ៨០០គ្រាប់ចឹងណា៎ៗ

បូលីៈ ស្ដាយរួចណា៎?

រុនៈ រួច! អាខ្លះ២កេះ! មានលេងណា៎ៗ ហើយគ្រាប់បេ៧០ណា៎ ម្នាក់១២គ្រាប់ៗ ៦២ម្នាក់១២! គ្រាប់បែកម្នាក់៣ទៅ៤សុង ហើយម្ដងសុទ្ធ៣០០នាក់ៗ ពួក១០៥ ទៅមណ្ឌលគិរីទៅ ពួកទន្លេសាបទៅទន្លេសាបទៅចឹងណា៎! ៤១៧ចូល ៤១៧ទៅរៀងៗខ្លួន អាខ្លះព្រៃវែងស្វាយរៀង ក៏ព្រៃវែងស្វាយរៀងទៅៗ ឆ្លងទួលៗចឹងនោះឯង ទៅអានោះ ឆ្លងអានេះទៀត វាយនៅមិនបាច់ឯងវាយឯណា មិនលេងឯណាៗ ហ៊ូ៎ខ្លាំងសម្បើម ណាស់ណា៎! មិនមែនមុខសញ្ញា តែយើងម្នាក់ណា៎ឡាប អាទូទាំងប្រទេសណា៎អូន កុំទៅលេងណា៎ វាខ្លាំងចឹង ហើយបងថា បានស្មើរខាងនេះ បងអរគុណណា៎បានរស់កុំ អីអត់ បានមកឃើញប្រពន្ធកូនចៅៗ

បូលីៈ ដើរប៉ុន្មានថ្ងៃបានដល់!

រុនៈ ១អាទិត្យនោះ!

បូលីៈ ដើររហូត?

រុនៈ ដើររហូត ពី១០០១ ទៅ! ពីអន្លង់វែងទៅភ្នំដីៗ

បូលីៈ ដើរពេលថ្ងៃ ឬពេលយប់?

រុនៈ យប់ក៏ដើរ ថ្ងៃក៏ដើរ! ១អាទិត្យឲ្យទៅដល់ ព្រោះបញ្ជាឲ្យទៅដល់ ព្រោះយើងត្រូវយកអីវ៉ាន់ទៅដាក់ទុកៗ បាញ់!

បូលីៈ ឆ្ងាយណាស់ពូ?

រុនៈ ហ៊ូ៎! ស្លាប់ហើយៗ

បូលីៈ កាត់ខេត្តព្រះវិហារទាំងមូល?

រុនៈ ថា១អាទិត្យៗ ស្វាទោសបទដើងគិចសិន! ដឹកទឹកអូនៗ

បូលីៈ ចុះពីអត់ទៅវាយហ្នឹងគេទេណា៎ គ្រាន់តែជញ្ជូនគ្រាប់ទេ?

រុនៈ អត់ទេ! គ្រាន់តែជញ្ជូនគ្រាប់ទេ ។ ពីឆ្នាំ៨០ បានខ្ញុំវាយ ៧៧,៧៧ ខ្ញុំវាយមែនជាមួយវៀតណាម ខ្ញុំវាយមែនហ្នឹង ។ វាយបាញ់គ្នា សម្លាប់គ្នា ធម្មតាវៀតណាមហើយហ្នឹងយើង យើងដឹងហើយណា៎! យើងត្រូវទឹកដីយើង ទឹកដីគេណា៎ បើចូលយើង យើងដាក់ហើយអាហ្នឹង៧៦ណា៎! ៧៧, ៧៨, ៧៩ប្រុច ហើយចាញ់រដ្ឋាភិបាលហើយណា៎នេះហើយប្រុច ។ ប៉ុណ្ណឹងទេ! រហូតដល់ទៅនៅភ្នំដី ។

បូលីៈ ពីត្រូវរបួសព្យាបាលហើយ លែងវាយហើយ?

រុនៈ លែងវាយហើយ ។ គេឲ្យពេទ្យដឹកជញ្ជូនមក ប៉ុនវាយដែរ ។

បូលីៈ វាយដែរ?

រុនៈ វាយ! ដល់ពេលត្រូវការកងពិសេស លេខ(ស្តាប់ពុំបាន) វាយដែរហើយ ។ នៅកន្លែងមន្ទីរគាត់ណា៎ ។ ទល់តែគាត់ហៅឥលូវអើ ពួក៥២,៥៣ណា៎ គេប្រគល់សមរភូមិត្រូវវាយណា៎ នោះភូមិនោះ វាយមែន វាយៗចាញ់ វាយមកហើយសល់ម្នាក់ក៏វាយដែរ ។ គ្នាវា១០០នាក់ យើងវាយតែ៣០ទេវាយមែន ។ ប៉ុន្តែឆាប់យើងវាគេ ប៉ុន្តែគេឆាប់ដែរដឹកសុទ្ធតែរទះសេះ ប្រពន្ធខ្ញុំអីវាយតាំងពីម៉ោង៨រហូតដល់ភ្លឺ ។ អាយុវែងដែរ គិតទៅចុះគេបងសម្លាប់យើង យើងមិនសម្លាប់គេ គេសម្លាប់យើងមិនចឹង ត្រូវតែលាងសិន!

បូលីៈ ចុះដល់ពេល១០០១បែក ពូនៅឯណា?

រុនៈ មកនៅអើ១០០២!

បូលីៈ ១០០២?

រុនៈ ១០០២ ។

បូលីៈ ១០០២ កងពីណាគេ?

រុនៈ ១០០២យើងនៅអីលិចនោះ ។ ១០០១ បែកបាក់ រដ្ឋាភិបាលឡើងមកហើយ ខ្ញុំនៅកន្លែងតាម៉ុក ។

បូលីៈ ១០០២ ឬក៏១០០៣?

រុនៈ ១០០៣ ។

បូលីៈ ១០០៣!

រុនៈ នេះ អាកន្លែងនេះណា៎ ។

បូលីៈ គេហៅអី?

រុនៈ គេហៅ១០០២តែម្តងអាហ្នឹង ១០០២,១០០៣ហ្នឹង ។

បូលីៈ ឈ្មោះគេច្រើនកន្លែងគេមាន៨០៨, វាមាន៨០!

រុនៈ មានណា៎! ៨០៨ មានណា៎៨០, ភូមិ៨០ ភូមិចងកណា៎ ។

បូលីៈ ភូមិចងក! ពូនៅឯណា៎?

រុនៈ នៅ៨០ ។

បូលីៈ ៨០?

រុនៈ បាទ! ភូមិ៨០ នេះ!

បូលីៈ ភូមិ៨០ ។

រុនៈ នេះអានេះ ។

បូលីៈ នៅទល់មុខអូរស្វាយ?

រុនៈ អូរស្វាយហ្នឹងហើយ ។

បូលីៈ ពូនៅ៨០ចឹង?

រុនៈ ចេញពី១០០១មកណា៎ ។

បូលីៈ បាទ!

រុនៈ ហ្នឹងឯងនៅនោះ ។

បូលីៈ មកនៅ៨០ នៅកងនោះដែរ ឬកងអីគេ?

រុនៈ នៅហ្នឹងដដែរ ។

បូលីៈ ៨១៧ដដែរ?

រុនៈ គេអត់មានបំបែកទេ ។ គេនៅមូលតាមកងពលតែម្ដង ។

បូលីៈ បើខាង៨០១ គេមកនៅគ-៧?

រុនៈ បាទ! គេមកនៅគ-៧ ។ ខ្ញុំនៅ៨០វាជាប់គ្នា គ-៧អីហ្នឹងជាប់គ្នា ខាងលិចនេះ ។

បូលីៈ ពេលហ្នឹងអូរគ្រាវបង្កើតនៅ?

រុនៈ អូរគ្រាវរបស់ថៃហ្នឹង ថៃវាដាក់ឈ្មោះអូរគ្រាវរបស់វាណា៎! ព្រោះខ្ញុំ៨០ហ្នឹង ភូមិចងក ហ្នឹងវាអូរគ្រាវកណ្ដាលហ្នឹងហើយ ។

បូលីៈ ជំរុំអូរគ្រាវវាបង្កើតហើយ ឬនៅ?

រុនៈ ពេលនោះ?

បូលីៈ មានឈ្មោះហើយ ឬនៅ?

រុនៈ ពេលនោះ ទើបតែយើងទៅដល់បានមាន ។ ចឹងពីដើមមក មានតែអូរគ្រាវមានជំរុំឯណា! អត់មានទេ ។

បូលីៈ តែជំរុំជនភៀសខ្លួន ឮសួរថាបង្កើតហើយ ឬនៅ?

រុនៈ នៅទេ!

បូលីៈ នៅទេណ៎?

រុនៈ នៅ! ទល់តែយើងមកដល់បានវាមានកម្លាំង ហើយបានដាក់អូរគ្រាវចូលហ្នឹង ។

បូលីៈ អូ៎! បានន័យ ទល់តែ១០០១ហ្នឹងចូល ។

រុនៈ មកសិន! ក៏បង្កើតអរគ្រាវទៅ អូរគ្រាវជួរ បារាំងអី និយាយចឹងណា៎! តែប៉ុណ្ណឹងទេ បើបង្កើតអូរគ្រាវជួរ មានមនុស្សទៅ ទៅបង្កើតយ៉ាងម៉េច មានមនុស្សណាទៅ ។

បូលីៈ ចឹងបានន័យថាអូរគ្រាវនេះបង្កើតនៅឆ្នាំ៨៥ចឹង?

រុនៈ ៨៥ ។ ចេញពី១០០១ ហើយវាយ១០០១ឆ្នាំប៉ុន្មានទេ!

បូលីៈ ចុង៨៤?

រុនៈ ៨៥បានត្រូវ! អត់មានមនុស្សទេ ។

បូលីៈ មិននាំគ្នារត់ពី១០០១មក?

រុនៈ រត់ពី១០០១ ថៃដឹកណា៎ ខ្មែរយើងរត់មកលិចទាំងអស់ ។

បូលីៈ បាទ! ថៃដឹកមកណា៎!

រុនៈ ថៃដឹកមកទាំងអស់ ។

បូលីៈ មកតាមដីថៃ ។

រុនៈ ហ្នឹងហើយ! មកនៅភូមិ៤០ ។

បូលីៈ ភូមិ៤០ ។

រុនៈ ហើយនៅភូមិ៥០ ។

បូលីៈ ហើយហ្នឹង៥០?

រុនៈ ៥០! ហ្នឹងហើយ គេមានដាក់៥០ ។

បូលីៈ នេះ!

រុនៈ ហ្នឹងឯង ។

បូលីៈ ហើយបានបង្កើតអូរគ្រាវតាមក្រោយ?

រុនៈ អូរគ្រាវតាមក្រោយ ។ ប្រជាជនមូលតែម្តង ពីខ្មែរក្រហមណា៎!

បូលីៈ បាទ!

រុនៈ ហ្នឹងឯង ។

បូលីៈ អូរគ្រាវដែរ?

រុនៈ ជំរុំនោះឯង ។ កងទ័ព និងគ្រួសារកងទ័ពនៅហ្នឹងទាំងអស់ ។

| | |
|---|---|
| បូលីៈ | នៅអូរត្រាវដែរ? |
| រុនៈ | នៅអូរត្រាវដែរ ។ ខ្លះអត់នៅទេ និងជំរុំអាខ្លះគេមក ខ្លះអត់ទេតែគំរៀបដូរទៅកន្លែង ៥០នេះ ។ |
| បូលីៈ | គេនៅតាមព្រំដែន? |
| រុនៈ | តាមព្រំដែន ។ |
| បូលីៈ | តាមអូរ៥០អី! |
| រុនៈ | ហ្នឹងឯងតាមអូរ៥០ទៅលិចទៀត គេនៅតាមព្រំដែនទេ! អ្នកនេះទេដែលគ្មានរត់ទៅជំរុំណា ខ្ញុំឃើញចង់បាន ចង់រស់ ចង់ស៊ីអីចឹងទៅណា គេមកអូរត្រាវទៅ ។ |
| បូលីៈ | ប្រជាជន? |
| រុនៈ | ប្រជាជន! ខ្លះកងទ័ពមែនប៉ុន្តែគេថាចឹងទៅ គេមកជំរុំទៅ ។ |
| បូលីៈ | គេលែងចងច្បាំង ។ |
| រុនៈ | គេលែងចង់ច្បាំង ចង់អីហើយ មកៗទៅ! គេមិនទឹង យើងធ្វើម៉េចកម្លាំងប៉ុន្មានយើងធ្វើតាមលទ្ធិភាពរបស់យើងទៅ ។ |
| បូលីៈ | ពូនៅ៤០ហ្នឹងរហូត ឬក៏មានដូរដែរ មកអូរត្រាវ អូរអីដែរ? |
| រុនៈ | ដូរ! |
| បូលីៈ | ដូរទៅណាទៀត? |
| រុនៈ | ចេញពីនោះហើយ មកនៅអន្លង់វែង ។ |
| បូលីៈ | ចុះក្រោម ចុះភ្នំ? |
| រុនៈ | ចុះភ្នំតែម្តង គេដឹកមក ។ |
| បូលីៈ | ឆ្នាំប៉ុន្មាន? |
| រុនៈ | (ស្តាប់ពុំបាន)ដល់តែវាយរដ្ឋាភិបាលវាយរត់អស់ហើយតាមនេះ អស់រលីងហើយ មកគេដឹកមកពីជំរុំមកអន្លង់វែងហ្នឹង ។ |
| បូលីៈ | ចុះតាមប្រកណា? |
| រុនៈ | ជាំស្រងាំ ។ |
| បូលីៈ | ជាំស្រងាំយើងនេះហ៎? |
| រុនៈ | បាទ! |
| បូលីៈ | មុនដំបូងនៅឯណាពូ? |
| រុនៈ | មុនដំបូង? |

បូលី៖ បាទ!

រុន៖ ចុះពីលើភ្នំមក?

បូលី៖ បាទ!

រុន៖ អ៊ូ! នៅស្វាត ។

បូលី៖ ស្វាតយើង! ហ៊ូត្រូវហើយ៨១៧នែក?

រុន៖ ៨១៧ ។ ខ្ញុំដីហ្នឹងគេឲ្យខ្ញុំទៅដែរ ដីខ្ញុំនៅផ្ទះអាអូន ប៉ុន្តែខ្ញុំនឹកឃើញឲ្យទៅយកដីនោះខ្ជិល សម័យខ្មែរក្រហម ខ្ញុំអត់យកបងប្អូននៅៗទៅ ខ្ញុំមកនៅនេះដីខ្ញុំនោះ គេឲ្យខ្ញុំនោះបន្ទាប់ អូរមេម៉ាយទេ នៅនេះទៅបែកប្រពន្ធបែកកូននៅនេះ ចឹងទេ ។

បូលី៖ ពីមុនៗទៅនៅក្បែរតាកែវពកនោះ?

រុន៖ បាទ! ពីមុនៗស្នាក់នៅជាមួយតានោះដីខ្ញុំប៉ុណ្ណណើ ប៉ុន្តែដល់ក្រោយមក សមាហរណកម្ម ច្របូក ច្របល់ឲ្យគេទៅដីនោះ គេហៅទៅដែរប៉ុន្តែខ្ជិលដីនៅផ្លូវប៉ុណ្ណណើ ទួលក្រឡាញ់ ។

បូលី៖ ខ្ញុំចង់សុំសួរកន្លែងនេះតិចពូ ពេលដែលយើងមានការផ្ដាច់ខ្លួនពេលហ្នឹងឆ្នាំ៩៨ចឹង ពេលហ្នឹង មាន ប៉ុនមិនហ្នឹងកម្លាំងរបស់តាម៉ុក និងកម្លាំងតាប៉ុល មិនវាយគ្នា មូលហេតុអ្វីបានជា វាយគ្នា ។

រុន៖ វាយមួយសារហ្នឹងយើង សមាហរណកម្មវាខ្លះគេឡើងភ្នំ តាហៅឡើងភ្នំណា៎ ហើយបងនៅ ទួលស្វាយ ចឹងហើយដល់ពេលនោះយើងត្រូវធ្វើ ខ្ញុំធ្វើម៉ោង១១យប់ណា៎ សមាហរណកម្ម ចាក់ បើខ្ញុំមិនធ្វើនៅអូរស្វាយទេកងទ័ពទាំងអស់គ្នា មានតែ១០នាក់ទេត្រូវធ្វើ តាជុំគេចាប់ ទៅនោះបាត់ហើយ ស្ថានភាពជាមួយរដ្ឋាភិបាលបាត់ហើយ ។ បើតាជុំនៅ តាម៉ុកវាយ ចោល គាត់គេចខ្លួន បើមិនគេចយ៉ាងម៉េច ៨០៧ គាត់មេ ខ្ញុំ៨០៧មិនគាត់គេច ថា៨០៧ នៅអូរស្វាយក្បត់ តាម៉ុកថាណា៎ ។

បូលី៖ ថាចឹង?

រុន៖ ថាចឹង ថាក្បត់ៗ បើមិនចឹងចាប់មេវាយ៉ាងម៉េចហ្នឹងបាន ខ្ញុំគាត់នាំបងប្អូន អាសៀង អា(ស្តាប់ពុំបាន)ហើយ អាគាត់ហ្នឹងផ្ញើរថាចូលមកថាឲ្យចាប់ អើគេអូរដែលនៅកន្លែង តាម៉ុកឲ្យបាន ខ្ញុំក៏ទៅចាប់ អាប៊ូ(ស្តាប់ពុំបាន)នោះប្អូនជីដូនមួយតាឌុលហ្នឹងណា៎ មកទៅ ចាប់មានអីស្លាប់(ស្តាប់ពុំបាន) តាម៉ុក ចេញមកកុកៗចូលឡាបូ(laboratory) ព្រោះ ជំនាន់ហ្នឹងកាន់កាន់អាធំនៅអូរស្វាយកាលហ្នឹងក្រោយផ្ទះខ្ញុំ អូរស្វាយសព្វថ្ងៃនេះ ។ បបួល គ្នាហើយ ខ្ញុំដកកាំភ្លើង ខ្ញុំថានេះឯងឈប់និយាយជាមួយតាម៉ុក ឯងដូរលេខទៅជួបតាទុំ ហើយបើហែងមិនសារ៉េឲ្យអញទេ អញសម្លាប់ហែងចោល ។ ពូអើយ ពូឯងធ្វើចឹងមិន

ងាប់ ខ្ញុំហើយឥលូវមិនបាច់ស្លាប់ទេ ឥលូវទ្រូវធ្វើសមាហរណកម្មសិន ព្រោះអីរដ្ឋាភិបាលកំពុង ចូលអូរស្វាយយើងសុទ្ធសាច់ហើយ ។ កែ ពក(ស្តាប់ពុំបាន) អន្លង់វែងអស់ហើយ ចូលណ៎ បើយើងមិនចូលយ៉ាងម៉េច ទៅទប់ទល់យ៉ាងម៉េចរដ្ឋាភិបាល គេវាយពីអន្លង់វែងមកទៀត យើងមានអីអូរស្វាយងាប់ គេមករំលោភយកគោ យកក្របីខ្ទេចខ្ទីគ្មានសល់ ត្រូវតែធ្វើ ខ្ញុំធ្វើមែនចាប់ពិប បើថា(ស្តាប់) អានេះវាមិញ ព្រោះគាត់និយាយហើយថា ពីណានេះអ្នកចាត់ចែង បានខ្ញុំ ធ្វើពិបនេះ សួរតាថន អាសួនអីនេះនេះបងនៅសព្វថ្ងៃ គាត់ធ្វើប៉ូលីស គាត់បានសក្តិធំណ៎ ។ បាយទឹកអី តាជុំបញ្ជាដែរឲ្យខ្ញុំហៅមកតាសឿង នេះឃុំ ឪតាឆាន់នេះ ហៅមេៗ ទាំងអស់មកជួបខ្ញុំនៅអូរស្វាយនិងនៅអូរតាជុំ គ្រាប់បែកទៅនៅអូរតាជុំទៅនោះ គេហៅអូនឡើងមកនេះសិនចុះដល់ឡើងចឹងទៅវាថ្ងៃហ្នឹង វាឥលូវទាល់តែធ្វើបើមិនធ្វើងាប់ មានអីប្រាវ ។ ខ្ញុំបញ្ជាក់នោះ(ស្តាប់ពុំបាន ) អញបាញ់ចោលយើងត្រូវធ្វើហើយ បើមិនអញ្ចឹងទេ បាញ់ចោលបើរដ្ឋាភិបាលបាញ់ចូលហើយ ។ វាយមែន វាយទួលពង្រនោះភ្នំដាច់ មិនវាយចូលយ៉ាងម៉េច ខ្ញុំធ្វើបាត់ ។

បូលី: បានន័យថាកម្លាំងតាអ៊ីងលាង កម្លាំងតាជុំ វាយចូល?

រុន: បាទ! វាចូលនេះបណ្តោយ ហើយយើងនេះនៅតែអូរស្វាយ ។

បូលី: នៅអូរស្វាយស្រាប់?

រុន: បាទ! នៅអូរស្វាយស្រាប់ ឃើញទេ ។

បូលី: ធ្វើពីក្រៅផង ធ្វើពីក្នុងផង?

រុន: ធ្វើពីក្នុងផង ។ អីនោះក៏គេមក ខ្ញុំម៉ោង១១យប់ ព្រលឹមឡើងម៉ោង៧ ខ្ញុំធ្វើបណ្តោយ ។

បូលី: ១១យប់ថ្ងៃអីគេ?

រុន: មិនដឹងជាស្អីទេ ម៉ោង១១យប់នៅអូរស្វាយ ខ្ញុំពិបាកថ្ងៃណាស់ ថ្ងៃហ្នឹង វាច្របូលច្របល់គ្នាពេក អត់ចាំទេណ៎ អត់ចាំសោះ ។

បូលី: កម្លាំងពូមានប៉ុន្មាននាក់ពេលហ្នឹង?

រុន: ៣០នាក់ ។

បូលី: ៣០នាក់ ។

រុន: កម្លាំងគេរាប់រយ! ចុះបើមីង១ ពូរាប់រយនាក់ បើខ្ញុំ៣០នាក់ហ្នឹង ជួយសមាហរណកម្មគ្នា គ្រាន់តែស្រាប់នោះមិនអស់ ជួយឲ្យបានធ្វើគ្នា ជួយឲ្យបានរស់ណ៎ ។

បូលី: ប្រជាជនគាំទ្រទេ?

រុនៈ និយាយមិនគាំត្រយ៉ាងម៉េចអូនអើយ! គាត់អរណាស់ គាត់បានឃើងរស់ណាស់ យើងនៅធ្វើសង្គ្រាម បើមិនទប់ទល់ទេ យើងអត់មានធ្វើអីទេ ។

បូលីៈ ចឹងនៅអូរស្មាយអត់មានកម្លាំងតាម៉ុក?

រុនៈ កម្លាំងតាម៉ុក ទាំងអស់ហ្នឹងណា៎ ។ កម្លាំងគាត់មែន ប៉ុន្តែទៅលើភ្នំបាត់ហើយ យល់ទេ? ហ្នឹងចឹងទេ គេទៅអស់ហើយ ។

បូលីៈ អាពេលដែលកំពុងតែវាយ ពេលតាម៉ុកឡើងទៅម្តុំនេះ ។

រុនៈ ផ្តាច់គេអូចោល!

បូលីៈ ផ្តាច់គេអូចោល?

រុនៈ ផ្តាច់! ដល់ពេលនេះរត់ណា៎ រត់ដល់ខ្ញុំទើបភ្លង់កាំភ្លើងចុះចេញ ប្រពន្ធឡុយ៩០០បាតចុះៗភ្លាម បម្រុងទៅដល់៤០៣កុំអីបាញ់ចោលតាមេនៗ តាមេនកូនគាត់យកប្តីបារាំង!

បូលីៈ តាមេនប្អូនថ្លៃតាឌុលហ្នឹងហ៎? អ្នកគាត់គេអូពីណាគេ?

រុនៈ អាបូៗ អាបូនោះបងប្អូនគាត់បង្កើត ប្អូនថ្លៃ ។

បូលីៈ ប្អូន ឬក៏ប្អូនថ្លៃ?

រុនៈ ប្អូនថ្លៃ?

បូលីៈ ប្អូនថ្លៃបងឌុល! អ្នកកាន់គេអូតាម៉ុកអេ៎?

រុនៈ កាន់គេអូកន្លែងប្រជុំ ។

បូលីៈ កាន់គេអូកន្លែងប្រជុំ?

រុនៈ កន្លែងប្រជុំណា៎ នៅអូរស្មាយផ្ទះបងណា៎គេអូអាធំ ដល់ខ្ញុំរត់ទៅ គាត់អត់ធ្វើអីទេ គាត់សុំមួយរស់រួចខ្លួនគេអូរតាធំហ្នឹង គាត់ទុកឲ្យទាក់ទងទៅគាត់ចូលរដ្ឋាភិបាលស្អែកហើយណា៎ ។ បើ គាត់នៅគេសម្លាប់ចោល គាត់ទៅចុះទៅជាមួយបងជាមួយគាត់ណា៎ ។ បើគាត់មិនទៅ គេសម្លាប់ហើយ កុំអីតាម៉ុក ដាក់គិបហើយតាលាងនេះតោះ ។ ចឹងហើយត្រូវតែធ្វើទាំងបងគេចាប់ នេះបងខ្ញុំ ។

បូលីៈ ចាប់ដែរ?

រុនៈ ចាប់ដែរ ។

បូលីៈ ចាប់យកទៅណា៎?

រុនៈ គាត់ទៅរកត្រីឡូកងទ័ពខ្មែរក្រហមណា៎នៅអូរអន្ត្រង់ ដល់ហើយក៏កងទ័ពរដ្ឋាភិបាលចាប់យកទៅបណ្តោយ ទៅជាមួយតាជុំបណ្តោយ ទៅជុំគ្នានៅប្រាសាទស្រអែមនោះ ។

បូលីៈ នៅខាងស្រអែមណ៎?

រុនៈ ស្រែអែម ។ អ៊ូនិយាយទៅវាច្រើនណាស់ ។

បូលីៈ ពេលហ្នឹងមានប៉ះគ្នាទេជាមួយតាម៉ុកពេលហ្នឹង?

រុនៈ ពេលហ្នឹងដល់ពេលដែលតាម៉ុកឡើងទៅហើយ បងគាត់ហៅមេៗ បងហៅមេៗគិបតែម្ដង លោកសឿងអីចុះពីផ្ទះណា៎ នរណាឈ្មោះសឿង តាលាងគេមកឲ្យតាសឿងទៅជួបនៅកន្លែងជួបប្រជុំគេខបត្តម្តចុះមក ។ តាសឿងគាត់(ស្ដាប់ពុំបាន) ហៅគាត់ថាបងព្រោះគាត់អាយុបងខ្ញុំ ខ្ញុំមកពីកំពង់ចាមនៅខេជ៉ាវ៉ា ខ្ញុំនៅធ្វើការហ្នឹង ពីណាឈ្មោះសឿង ខ្ញុំអត់ស្គាល់ដែលនៅទន្លេសាប នេះនៅអូរស្វាយជិតគាត់នៅតូចៗ(ស្ដាប់ពុំបាន) ចុះៗ អង្គរក្សគេ តោះទៅកន្លែងគេអូ ។

បូលីៈ គេអូនៅណា៎?

រុនៈ នៅអូរស្វាយ! ផ្ទះខ្ញុំនេះនោះដែលខ្ញុំចាប់អាបូហើយណា៎ អាបូទាក់ទងតាម៉ុកទេទាក់ទងតាលាងនៅស្រែអែម ហានតែទាក់ទងតាម៉ុក ខ្ញុំសម្លាប់ចោល ។

បូលីៈ បាញ់ចោលតែម្ដង?

រុនៈ បាញ់ចោលបណ្ដោល ។ វាអត់ហានទេ វាសុខចិត្ត នេះអាបូ សុងនេះមេព្រៃសព្វថ្ងៃ ។

បូលីៈ ភូមិអីគេ? អូរស្វាយហ្នឹង!

រុនៈ ភូមិអូរស្វាយបណ្ដោយ ។

បូលីៈ ភូមិស្វាយតែម្ដង! ចឹងនៅក្បែរជើងភ្នំ ។

រុនៈ បាទ! នៅក្បែរជើងភ្នំ អូរស្វាយបណ្ដោយ ផ្ទះខ្ញុំនៅក្បែរហ្នឹងពីដើមនោះ នៅអូរស្វាយ ។

បូលីៈ យើងជុំគ្នានៅទីនេះទាំងអស់តែម្ដង?

រុនៈ នៅជុំគ្នារាប់រយ ។

បូលីៈ បានប៉ុន្មានកម្លាំងបានមកជុំគ្នា?

រុនៈ មានតិចណា៎(ស្ដាប់ពុំបាន)! និយាយថាកម្លាំងដែលធ្វើ តែ១២នាក់ទេ ។ ១២នាក់ធ្វើបានមនុស្សជិតរាប់ម៉ឺននាក់ស្អាតតែម្ដង កុំតែតាឆាំទេ មេកងទ័ព ៤១៧នៅអន្លង់វែង គាត់វាយតុទេ ។ កាលហ្នឹងហ្នឹង បីសខ្ញុំបាញ់ចោល នឹកឃើញមេខ្លួនឯង ។

បូលីៈ គាត់វាយតុថាម៉េច?

រុនៈ គាត់វាយតុថាអាណាអ្នកធ្វើ! ខ្ញុំទះតុមាំង (ស្ដាប់ពុំបាន) អាមេប៉ូលីសសព្វថ្ងៃ ។

បូលីៈ កែវ តាំហ្នឹង?

រុនៈ គាត់វាយតុមាំង! គាត់ចាប់យកតែម្ដង ចាប់ទាញយក(ស្ដាប់ពុំបាន) ខ្ញុំថានែក នៅឲ្យស្មៀមគេអូអាតូចៗនោះ បើនេះទៅខ្ញុំជាន់ចោល ។ តា ឆាំយើងមាឌធំ(ស្ដាប់ពុំ បាន)

គាត់វាយតុ គាត់ចង់ថាមិនឲ្យចាញ់គេ បើខ្ញុំធ្វើសមាហរណកម្មទៅហើយ មិនចាញ់យ៉ាងម៉េចបើគាត់វាយតុចឹង ។ អញអ្នកធ្វើ! មើលអាណាខ្លាំង (ស្តាប់ពុំបាន) អត់ហានដែរ ។ (ស្តាប់ពុំបាន) ពួកកម្លាំងប៉ុន្មានាក់ ពេញទឹកពេញដី កំពុងតែស្រវឹងផង! ខ្ញុំអ្នកធ្វើហើយទៅមិនបាច់ទេអូន ធ្វើហើយ ធ្វើខ្លួនឯងម៉ោង១២យប់ព្រលឹមឡើងម៉ោង៧ស្គួរប្រពន្ធខ្ញុំបើចាញ់តាម៉ុកច្បាស់ គេសម្លាប់ប្រពន្ធកូន ខ្ញុំបែកផ្លូវរត់ចឹងទៀតណា៎ ខ្ញុំសុំប់ណាស់ណាខ្ញុំប្រាប់ ។

បូលី៖ ចុះពេលហ្នឹងកែវ តាំហ្នឹង តាឆាំ គាត់នៅខាង(ស្តាប់ពុំបាន) ឬនៅខាងពូ?

រុន៖ ទេ! នៅជុំគ្នា ។

បូលី៖ ចុះទះតុធ្វើអី?

រុន៖ គាត់ចង់ថាអ្នកណាធ្វើ គាត់មិនចង់ឲ្យចាញ់រដ្ឋាភិបាលទេចេះ ។

បូលី៖ ចឹង?

រុន៖ បាទ! អាគីមជាមួយខ្ញុំ គាត់ថាត្រូវតែធ្វើ បើមិនធ្វើទេងាប់ប្រជាជនទាំងអស់ ។

បូលី៖ កែវ តាំ គាត់អត់ចង់ចុះចូលទេ?

រុន៖ អត់ចង់ចុះចូលទេ!

បូលី៖ គាត់ចង់នៅជាមួយតាម៉ុកទៀត?

រុន៖ ហ្នឹង ។ មកពីកំពង់ចាមជុំខ្ញុំហ្នឹងឯង មកដល់គាត់វាយតុតែម្តង ។

បូលី៖ ម៉េចបានជាមិនចង់ចុះចូលបើកែវ តាំ ហ្នឹងគាត់ជាប់ទ្រុងតាម៉ុក?

រុន៖ នោះឯងគាត់ថា ជាប់ទ្រុងតាម៉ុក! គាត់កំពុងទាក់ទង គាត់ហ្នឹងបងប្អូនខាងតា ពកគាត់ខាងអី នៅទាក់ទងតាម៉ុកណា៎ បើសិនជាគាត់ក្បត់តាម៉ុកគាត់ថាខ្មាសគេណា៎ ដល់ពេលខ្ញុំមានឲ្យ មិនសម្លាប់ណា៎ ខ្ញុំធ្វើឲ្យរួចសមាហរណកម្ម គាត់បាន គាត់អគុណសម្លាសន៍កូល្អណាស់ ។ ចេះ! ខ្ញុំនេះទៅកាន់ព្រលានយន្តហោះនៅថ្កូវនោះ ។

បូលី៖ នៅថ្កូវ ។

រុន៖ នៅកន្លែងកងពល១៩ទេ(ស្តាប់ពុំបាន) ដល់ពេលសមាហរណកម្មទៅផ្តាច់ទៅចឹង អស់រលីងទៅ គេឲ្យខ្ញុំធ្វីការងារធំដែរ ។ គេឲ្យចាំព្រលានយន្តហោះកន្លែង ។

បូលី៖ ភូមិព្រលានមែនទេ?

រុន៖ ភូមិព្រលានកន្លែងថ្កូវណា៎ ជាមួយ៩៩ អាកន្ទុំរុយគេចុះចំណីអាហារកងទ័ពណា៎ ។

បូលី៖ បាទ!

រុនៈ ថ្ងៃសមារណេកម្មរួចនោះ មិនយន្តហោះដាក់ហ្នឹង គេឲ្យខ្ញុំនៅហ្នឹង ដល់ខ្ញុំថាខ្ញុំមិនធ្វើទេឈប់ហើយ ។ បានសមាហរណេកម្មរួចប៉ុណ្ណេះ ខ្ញុំអរគុណណាស់លោកឯងទាំងអស់គ្នាឲ្យខ្ញុំធ្វើ ៩៩ ឬក៏១៩ ។ ឲ្យខ្ញុំធ្វើមិនមែនតូចទេណា៎!

បូលីៈ ធ្វើអីគេ?

រុនៈ គាត់ឲ្យធ្វើនែក អនុសេនាធំ ឯខ្ញុំវីរៈទេ ដល់ពេលសម័យនោះ គេឲ្យខ្ញុំអនុសេនាធំខ្ញុំថាអត់ធ្វើទេ ខ្ញុំអរគុណហើយប៉ុណ្ណឹងបានហើយ សួរប្រពន្ធខ្ញុំកូនខ្ញុំ ខ្ញុំឈប់ធ្វើឈប់អីហើយ ព្រោះឆ្អែតហើយ ខ្ញុំទៅរកស៊ីចញ្ចឹមប្រពន្ធខ្ញុំម្តង ។

បូលីៈ ពេលតាលាង វាយចូលមក ពេលហ្នឹងម្ចាស់ដីពូនៅឯណា?

រុនៈ នៅអូរស្វាយ ផ្ទះខ្ញុំ ។

បូលីៈ ពូចាំទទួលនៅនេះស្រាប់?

រុនៈ នេះស្រាប់!

បូលីៈ គាត់វាយពីនោះមក?

រុនៈ អត់មានវាយទេ ដើរចូលបណ្តោយ បើសិនជាមកកុំឲ្យធ្វើបាបបងប្អូនមក តាដុំក៏ដោយកម្លាំងគាត់ណា បើសិនជាធ្វើបាបអីនេះទៀតមិនបាច់ចូលទេ ។ ទៅយើងថាសមាហរណេកម្មផ្តាច់ខ្លួនទាំងអស់គ្នា បានហើយ បើសិនមកដល់ ចង់ពីសម័យអាពត ដូចថាប្អូនឯង ជាប់គំនុំបង បងធ្លាប់គំនុំអូនឯង ចឹងណា៎! កុំអីអានោះបាញ់ចោល ទេអត់បានទេ! យ៉េគំនុំគ្នាសម័យប៉ុល ពតគំនុំគ្នាណា ។ ដល់តែគំនុំគ្នា គេថ្វាសមាហរណេកម្មគេនោះមក អានោះចង់ខ្លាំង អាណាខ្លាំងពីខ្មែរប៉ុល ពត គេចាប់បាញ់ចឹងណា៎ ។ ហើយថាអត់ទេ បើបាញ់មកសួរតា(ស្តាប់ពុំបាន) សួរទៅៗ ខ្ញុំនិយាយថ្ងៃៗណាអូន ។ បងវាឆ្អែតហើយ ឃើញថាបានខ្ញុំលា ឈប់(ស្តាប់ពុំបាន) មកនៅប្តីប្រពន្ធវិញការងារ (ស្តាប់ពុំបាន) រហូតដល់ពេលធ្វើការនោះអូសឆ្នោតទៅទៀតឡាំង អាពួកគេបាញ់ឆេះតាមផ្លូវ ខ្ញុំអូសកាត់ព្រៃបណ្តោយ ។

បូលីៈ ពីណាគេអ្នកបាញ់?

រុនៈ អានេះ! អាកន ។

បូលីៈ កនណាចេះ?

រុនៈ អាកននោះនៅ ។

បូលីៈ កងពលណា៎?

រុនៈ ៤១៧ហ្នឹង ។ វាបាញ់អាត្រាក់មេ៤១៧ហ្នឹងណា៎! បាញ់អាត្រាក់មេ៤១៧ហ្នឹងណា៎ ។ អាត្រាក់(ស្តាប់ពុំបាន) ឆ្នោតហ្នឹងណា៎ ។

បូលីៈ ពេលហ្នឹងយើងមិនបោះឆ្នោតឆ្នាំ៩៨?

រុនៈ បោះនៅអូរស្វាយកណ្តាលព្រៃនោះ?

បូលីៈ អូរស្វាយ?

រុនៈ អូរស្វាយ ។

បូលីៈ ពេលហ្នឹង តាម៉ុក នៅលើភ្នំ?

រុនៈ តាម៉ុកនៅលើភ្នំ ។

បូលីៈ តាម៉ុក ឡើងលើភ្នំហើយៗ?

រុនៈ បាទ!

បូលីៈ ព្រោះថាកម្លាំងខាងតាជុំគេមកហើយ?

រុនៈ ចូលមកហើយ ហើយពួកតាម៉ុកនៅនោះ ។

បូលីៈ បាទ!

រុនៈ គេនៅព្រៃ ហើយយើងក៏(ស្តាប់ពុំបាន) ទៅ តាជុំឲ្យមកក៏អាត្រាក់មួយ តាម៉ុកឲ្យហ្នឹង អាត្រាក់ហ្នឹង អាត្រាក់ឲ្យតាម៉ុកឲ្យទេ ឲ្យវាដឹកសន្លឹកឆ្នោតទៅទួលគ្រួសដាក់បាំង ផាប់តាឃីម និង អាញ៉ន ប្តីមីសេង ឡេងនេះហ្នឹង ។ ដល់ពេលអស់(ស្តាប់ពុំបាន) ពួកនោះបាញ់ថែមទៀត ឡើងបានឲ្យដុតអាត្រាក់អស់រលីង ។ គេមកហៅខ្ញុំ គេថាកន្លែងអូសឡើងសន្លឹកឆ្នោតទៅ មានតែតាកក និងអាចេក ទេអូសបាន ។ នេះអាចេកកណ្តាលថ្ងៃ មានតែតាកកទេ អូសសន្លឹកឆ្នោតបាន បើតាកក អូសមិនបានទេ ខ្ញុំប្តេជ្ញាបណ្តោយ ខ្ញុំទាញកាំភ្លើងបេ-៧០ ខ្ញុំបណ្តោយ អា១ដើម សួរប្រពន្ធខ្ញុំ ខ្ញុំអូសកម្លាំង៣០នាក់ទាញ! អាអ្នកស្វាយៗ អាឃីមនេះ គាត់អ្នកដើរជាមួយ ខ្ញុំទាំងអស់មេណា៎! មកដល់ជួបមុខព្រាក ខ្ញុំដាក់មាំងៗៗ(ស្តាប់ពុំបាន) គេថារោលៗខ្លាំង ម៉្លេះ ប្រយ័ត្ន អាពតវាយចេះ(ស្តាប់ពុំបាន) គេឆ្លងរាល់ថ្ងៃមកវាយផ្លូវនេះ ខ្ញុំប្រាប់ទៅ ។ ខ្ញុំអូសទៅដល់ ម៉ោង៩ព្រឹក ខ្ញុំដើរតាមផ្លូវតែម្តង ខ្ញុំដើរមើលស្អាតសណ្តាប់ធ្នាប់ អ្នកស្វាយនៅឯក្រោយ អាអ្នក(ស្តាប់ពុំបាន) នៅកណ្តាល បីឡាំងនៅកណ្តាល ។

បូលីៈ បីឡាំង?

រុនៈ បីឡាំង! ចុះបើឡាំងយើងបីនោះ ដើរៗបង់វ៉ាឯងទទួលខុសត្រូវ ខ្ញុំទៅមុន ហើយបង់វ៉ាឯងបិទគេអូ ទុកឲ្យខ្ញុំ!មានអី (ស្តាប់ពុំបាន)ទៅដល់ខ្ញុំបាញ់ អស់ប៉ុន្មានគ្រាប់ បានចូលអូរជួរ

ស្វាយ នេះលោកសឿនៗ គាត់ឡើងគ្នោតឲ្យ! គេអរគុណណាស់ គេបោះកណ្ដាលព្រៃ បោះអី ថ្ងៃហ្នឹងៗ ចុះកណ្ដាលព្រៃ បោះអាគេអូនោះ បងប្អូនថាអាគេអូនោះចឹងៗណា៎ វាមានសិទ្ធឯណាចេះតែបោះទៅ ដើម្បីបន្ដ្រប់កិច្ចរដ្ឋាភិបាលនោះ ជាមួយតាអីខៀវសំផន ផងចឹងនែក មួយសារហ្នឹងមិនចឹងនោះឯងៗ ហើយយើងមិនបាច់ឈ្នះគេទេ គេរកអីយើង គេឲ្យមក ចេះតែរបស់ខ្មែរដាក់ នៅហ្នឹងមិនដឹងៗ យកមកបោះ!

បូលីៈ បោះសម័យអ៊ុនតាក់ ឬក៏សម័យ៩៨?

រុនៈ សម័យ៩៨នេះឯងៗ

បូលីៈ ៩៨ៗ

រុនៈ អ្នកទៅបោះច្រើនទេ?

បូលីៈ ចុះបងប្អូនភូមិយើងអូរស្វាយដែលផ្ដាច់ខ្លួននៅពេញហ្នឹងបោះទៅ នៅពេញហ្នឹងបោះទៅៗ

រុនៈ ចុះទំនប់ដាច់ គេមានបោះទេ?

បូលីៈ ទំនប់ដាច់ហេ៎?

រុនៈ ទំនប់ដាច់ អាហ្នឹងផ្សេងៗ

បូលីៈ បោះផ្សេង?

រុនៈ បោះផ្សេង នៅឃុំអូរស្វាយយើងបោះនៅហ្នឹងទាំងអស់ៗ

បូលីៈ ចឹងអាហឹបបីហឹបហ្នឹង នេះទាំងអស់?

រុនៈ ខ្ទេច! ឆាប់មនុស្សទៀត ឆាប់តាឃីមៗ

បូលីៈ អត់បារាប់ផងហេ៎?

រុនៈ ទេបោះហើយ!

បូលីៈ គេរាប់សន្លឹកឆោតហើយៗ?

រុនៈ ទេទុកដាក់ទៅហ្នឹង!

បូលីៈ មិនទាន់បានបោះផងហ្នឹងៗ

រុនៈ មិនទាន់បានបោះផងហ្នឹងៗ ដឹកឡាំងមកបានអាត្រាក់ចេញ ប្រជុំអាត្រាក់ផងនោះ តាម៉ុក ឲ្យប្រជុំនោះៗ មកគ្មានទេ ភឹងៗ! (ស្ដាប់ពុំបាន) អានេះបាក់ជើង គេបាញ់ថែម គ្នាឯងៗ ប្រយុទ្ធគ្នាឯងចឹងណា៎ មិនខ្វាចស្លាប់ ហ៎ូ! អូនអើយឡើង ដល់តាជុំបញ្ជាទល់ តែហៅអាកកមកបានៗ ឃើញទេដល់ពេលជិតដាច់ខ្យល់បានហៅមកបាន ព្រោះតែ អាកកអាចេកទេដែលយកឡើងទៅបានសួរគណឃុំគណស្រុកនៅនោះ ខ្ញុំណាស្ដាយកាត់

ព្រៃតែម្តង ឃើញទេ។ អត់ចង់បានតំណែង បានអីទេ សូម្បីអស់លោកឃុំ អីទៅ ខ្ញុំមានការងារកុំខឹងអីខ្ញុំពេក ខ្ញុំ អរគុណហើយ ។

បូលី៖ បច្ចុប្បន្នពូ ធ្វើអីពូបច្ចុប្បន្ន?

រុន៖ អត់ធ្វើអីទេ ។

បូលី៖ ចូលនិវត្តន៍ហើយចឹង?

រុន៖ បាទ! អត់ធ្វើអីទេ ។

បូលី៖ ពូអត់ចង់ធ្វើអីសោះ?

រុន៖ អត់ទេ! ព្រោះខ្ញុំវាអស់ហើយអូនអើយ ដូចថាវាជួយបងប្អូនវាឆ្អែតហើយ ឲ្យខ្ញុំធ្វើអីទៀត ធ្វើការដើម្បីដិះដាន់រឹបអូស បងប្អូនយើង ខ្ញុំអត់ធ្វើទេ។ សុខចិត្តនាំប្រពន្ធនាំកូនទៅធ្វើស្រែចម្ការនោះ រកស៊ីទេចិញ្ចឹមជីវិតយើងទៅ ធ្វើអីៗឲ្យសមរម្យជាមួយ រដ្ឋាភិបាលយើងបានហើយ កុំឲ្យមានរឿង ។

បូលី៖ ខ្ញុំដូចថារំខានពូយូរដែលហើយ ចឹងសុំ សម្ភាសន៍ពូត្រឹមហ្នឹងចុះ! អរគុណពូច្រើនដែលបានជជែកលេង ។

រុន៖ បាទ!

«ចប់»